# ១-សិទ្ធិស្ត្រីក្នុងព្រះពុទ្ធសាសនា

ស្ត្រីនិងបុរសមានសិទ្ធិស្មើគ្នាឬទេ ?

សំណួរនេះ បើចំពោះពុទ្ធបរិស័ទ ដែលសិក្សាដោយល្អនូវព្រះធម៌ ជាពាក្យទូន្មានរបស់ព្រះសម្មាសម្ពុទ្ធ ក៏រមែងឆ្លើយបានយ៉ាងច្បាស់លាស់ថា «ស្ត្រីនិងបុរសមានសិទ្ធិស្មើគ្នាក្នុងផ្លូវព្រះពុទ្ធសាសនា ដ៏យ៉ាងពិតប្រាកដ »។

**សិទ្ធិ** ប្រែថា សេចក្ដីសម្រេច គឺជាអំណាចមួយដែលប្រកបដោយធម៌ ។ ក្នុងវចនានុក្រមខ្មែរ មានពាក្យប្រែច្រើន ក្នុងនោះមានពាក្យប្រែថា « អំណាច »ផងដែរ ប៉ុន្តែក្នុងរឿងសិទ្ធិស្ត្រីនេះ ខ្ញុំព្រះករុណា ខ្ញុំបាទ សូមអធិប្បាយថា « អំណាចដែលប្រកបដោយធម៌ » ព្រោះមិនមែនជាសិទ្ធិអំណាចដែលត្រូវសម្លាប់ ឬត្រូវនិរទេសជនដទៃជាដើមនោះឯណា នេះគ្រាន់តែជាសិទ្ធិមួយដែលអាចសម្រេចបាន តាមសមត្ថភាពរបស់ខ្លួន ប្រកបដោយធម៌



តែប៉ុណ្ណោះ ពោលគឺប្រាសចាកទោសគ្រប់យ៉ាង ។

កាលបើសិទ្ធិ គឺជាអំណាចប្រកបដោយធម៌ ក៏សម្ដែងបញ្ជាក់ថា ស្ត្រី និងបុរស រមែងមានសិទ្ធិស្មើគ្នា ព្រោះពាក្យថា « ប្រកបដោយធម៌ » ក្នុងទីនេះ រាប់ថាជាគុណជាតិមួយដ៏ល្អស្អាត និងត្រឹមត្រូវ មិនទំនាស់នឹងគោលព្រះពុទ្ធសាសនា ។ ដូចដែលពុទ្ធបរិស័ទយើងបានជ្រាបគ្រប់គ្នាហើយថា ព្រះពុទ្ធសាសនា ជាសាសនាដែលបើកទូលំទូលាយ សម្រាប់មនុស្សគ្រប់ភេទ គ្រប់វ័យចូលមករាប់អាន ។ បុរសផង ស្ត្រីផង ចូលមកក្នុងព្រះពុទ្ធសាសនា មានការងាររួមគ្នា ប្រកបដោយទឹកចិត្តជ្រះថ្លា ក្រោមម្លប់នៃពាក្យទូន្មានប្រៀនប្រដៅរបស់ព្រះសម្មាសម្ពុទ្ធ ។ កាលបើសិក្សាកាន់តែមានជម្រៅ មនុស្សយើងទាំងស្រី ទាំងប្រុស រមែងមិនឈ្លោះគ្នាឡើយ មិនតាំងទុកគ្នាជាសត្រូវ ត្រឡប់បែរទៅជា មានសត្រូវ គឺកិលេសរួមគ្នាវិញ ពោលគឺរួមគ្នាសិក្សា នាំគ្នាបដិបត្តិ ឱ្យកម្លាំងចិត្តគ្នា មានមេត្តាករុណាដល់គ្នា ដើម្បីជម្រះមន្ទិល

សៅហ្មងក្នុងចិត្តសន្តានរៀងៗខ្លួន ។ មន្ទិលសៅហ្មងគឺជាកិលេសទាំងឡាយនេះហើយ ដែលជាសត្រូវរបស់ព្រះពុទ្ធ-សាសនា ដូច្នេះ ទាំងប្រុសទាំងស្រី ត្រូវតែមានសិទ្ធិស្មើគ្នា ក្នុងការកម្ចាត់បង់សត្រូវគឺកិលេសនេះឯង ។

ម្យ៉ាងទៀត ព្រះពុទ្ធសាសនាបានសម្តែងថា មនុស្សយើង កើតមករមែងមានទុក្ខ ។ ជាតិទុក្ខ ជរាទុក្ខ ព្យាធិ-ទុក្ខ និងមរណទុក្ខ គឺជាសភាវទុក្ខ តែងមានជាប្រចាំគ្រប់គ្នាទាំងអស់ មិនថាមានក្រ ល្អអាក្រក់អ្វីឡើយ ។ ទាំងអស់គ្នាដែលជាអ្នកមានបញ្ញា សុទ្ធតែត្រូវការឱ្យរួចផុតចាកទុក្ខទាំងនោះដូចគ្នា ហើយការដែលអាចរួចផុតចាកទុក្ខទៅបាន មិនមែនស្ថិតនៅលើភាវៈជាប្រុសឬជាស្រីនោះឡើយ គឺវាស្ថិតនៅត្រង់ការអប់រំបញ្ញា ដែលជាផ្នែកនៃការចម្រើនផ្លូវចិត្ត ឯណេះដោយឡែក ។

ក្នុងបិដកលេខ ៣០,ទំព័រ ៣ ក្នុង **សោមាសូត្រ** មារមានចិត្តបាប បានពោលទៅរកព្រះនាងសោមាភិក្ខុនីដូច្នេះថា « ព្រះអរហន្តណា ដែលមានដោយក្រ ជាទី



ដែលអ្នកស្វែងរកទាំងឡាយគប្បីដល់ ទីនោះស្ត្រីដែលមានបញ្ញាត្រឹមតែពីរធ្នាប់ [១] មិនអាចនឹងដល់បានឡើយ » ។ ព្រះនាងសោមា បានពោលតបទៅមារមានចិត្តបាបវិញថា « កាលបើចិត្តតាំងមាំល្អហើយ ញាណប្រព្រឹត្តទៅហើយ ភាវៈជាស្រី នឹងមកធ្វើនូវការរារាំងអ្វីដល់បុគ្គលអ្នកឃើញនូវធម៌ដោយប្រពៃ [២] » ។

ក្នុងព្រះពុទ្ធសាសនា បដិសេធរបៀបរបបក្នុងសាសនាព្រាហ្មណ៍ ដែលប្រកាន់វណ្ណៈរហូតមកដល់សព្វថ្ងៃ ។ ព្រះអង្គត្រាស់ថា « ដែលជាព្រាហ្មណ៍នោះ មិនមែនឋិតនៅលើជាតិកំណើតទេ គឺឋិតនៅលើការប្រព្រឹត្តរបស់មនុស្ស » មានសេចក្តីពិសេសនៅក្នុងបិដកលេខ ២៥ វាសេដ្ឋសូត្រ :

**ន ជច្ចា វសលោ ហោតិ** បុគ្គលថោកទាបមិនមែនព្រោះជាតិទេ ។

**ន ជច្ចា ហោតិ ព្រាហ្មណោ** បុគ្គលដែលជា

---

១-សំដៅត្រង់ប្រើម្រាមដៃពីរចាប់ត្រល់រុំអំបោះឬសូត្រសម្រាប់ត្បាញ ។

២-ឃើញសច្ចធម៌ទាំង ៤,ឬឃើញបញ្ចក្ខន្ធដែលជាអារម្មណ៍របស់វិបស្សនា។

ព្រាហ្មណ៍ ក៏មិនមែនព្រោះជាតិដែរ ។

**កម្មុនា វសលោ ហោតិ** បុគ្គលថោកទាប ព្រោះកម្ម (គឺការប្រព្រឹត្តក្នុងបច្ចុប្បន្ន) ។

**កម្មុនា ហោតិ ព្រាហ្មណោ** បុគ្គលដែលជាព្រាហ្មណ៍ ក៏ព្រោះកម្មដែរ[១] ។

ដែលព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់ហៅថា **ព្រាហ្មណ៍** ក្នុងទីនេះ គឺបុរសក៏ដោយ ស្ត្រីក៏ដោយ ឱ្យតែជាអ្នកកម្ចាត់បង់នូវបាប គឺព្រះអង្គត្រាស់ហៅថាជា ព្រាហ្មណ៍ទាំងអស់ ។ ឯការថោកទាប ក៏មិនមែននៅលើស្រីឬប្រុសនោះទេ គឺនៅលើការប្រព្រឹត្តថោកទាបហ្នឹងឯង[២] ។

ក្នុងគាថាធម្មបទ ព្រាហ្មណវគ្គ ព្រះអង្គត្រាស់ហៅព្រះនាងភិក្ខុនីជាច្រើនអង្គថាជាព្រាហ្មណ៍ គឺ :

## ព្រះនាងបជាបតិគោតមី

អ្នកណាមិនមានសេចក្តីអាក្រក់ ដោយកាយ វាចា

១.បិដកលេខ ២៥, ទំព័រ ២២២ ។

២.បិដកលេខ ៥៤ ,ទំព័រ ៤២ វសលសូត្រ ។



ចិត្ត តថាគតហៅអ្នកនោះ ដែលបានសង្រួមហើយ ដោយឋានៈទាំង ៣ យ៉ាងថាជាព្រាហ្មណ៍ ។

## ព្រះនាងកិសាគោតមី

តថាគតហៅជនដែលស្លៀកសំពត់បង្សុកូល មានរូបរាងកាយស្គាំងស្គម មានសរសៃរវីមរវាម ចម្រើនឈាននៅក្នុងព្រៃតែម្នាក់ឯងនោះថាជាព្រាហ្មណ៍ ។

## ព្រះនាងឧប្បលវណ្ណាថេរី

អ្នកណាមិនជាប់ជំពាក់ក្នុងកាមទាំងឡាយ ដូចជាទឹកមិនជាប់លើស្លឹកឈូក ឬដូចជាគ្រាប់ស្ពៃមិនជាប់លើចុងដែកដែលស្រួច យ៉ាងនោះឯង តថាគតហៅអ្នកនោះថាជាព្រាហ្មណ៍ ។

## ព្រះនាងខេមាភិក្ខុនី

តថាគតហៅបុគ្គលដែលមានបញ្ញាជ្រៅជ្រះ ជាអ្នកប្រាជ្ញ ឈ្លាសវៃក្នុងផ្លូវ និងមិនមែនជាផ្លូវ បានសម្រេចនូវប្រយោជន៍ដ៏ខ្ពង់ខ្ពស់នោះថាជាព្រាហ្មណ៍ ។

## ព្រះនាងធម្មទិន្នាថេរី

សេចក្តីខ្វល់ខ្វាយ ក្នុងពេលមុន ពេលជាខាងក្រោយ និងក្នុងពេលជាកណ្តាល របស់អ្នកណាមិនមានទេ តថាគតហៅអ្នកនោះ ដែលជាអ្នកមិនមានកង្វល់ និងមិនមានការប្រកាន់មាំថាជាព្រាហ្មណ៍ ។

កាលបើដូច្នេះ យើងត្រូវយល់ដល់ព្រះពុទ្ធសាសនា ដែលជាសាសនាឱ្យឥស្សរភាពដល់មនុស្សគ្រប់គ្នា គ្រប់ជាន់វណ្ណៈ គ្រប់ភេទ គ្រប់វ័យ ដោយចំពោះគឺនៅត្រង់សមត្ថភាពខាងផ្លូវចិត្ត ។ ទាំងស្រីទាំងប្រុសមានអំណាចក្នុងការអភិវឌ្ឍខ្លួនឯង ឆ្ពោះទៅរកការរួចផុតចាកទុក្ខបានដូចគ្នា ទាំងដែលព្រះអង្គទ្រង់ឱ្យសេចក្តីសំខាន់ចំពោះបុរស និងស្ត្រីប៉ុនៗគ្នាទៀតផង ។ ព្រះសម្មាសម្ពុទ្ធទាំងឡាយទ្រង់បានកើតឡើងក្នុងលោក មិនមែនដើម្បីប្រយោជន៍ចំពោះតែបុរសនោះទេ ព្រះអង្គទ្រង់កើតឡើងក្នុងលោក ដើម្បីប្រយោជន៍ដល់ស្ត្រីផង ដូចគ្នាដែរ ។ ផ្លូវនៃការរួចផុតចាកទុក្ខ បើកទ្វារទទួលទាំងស្រីទាំងប្រុស ។



ពោលចំពោះព្រះគុណនៃព្រះសម្មាសម្ពុទ្ធ ព្រះអង្គទ្រង់មាននូវព្រះហឫទ័យមេត្តាករុណា ដល់សព្វសត្វទាំងអស់ស្មើៗគ្នា ។ សព្វថ្ងៃមានមនុស្សមិនតិចនាក់ឡើយ ដែលយល់ថា ស្ត្រីមានសិទ្ធិតិចជាងបុរស ដោយចំពោះក្នុងរឿងបព្វជ្ជាឧបសម្បទា ។ យ៉ាងណាក៏ដោយ សម្រាប់ព្រះសម្មាសម្ពុទ្ធ ព្រះអង្គទ្រង់ឱ្យសិទ្ធិយ៉ាងពិតប្រាកដ ក្នុងវិន័យបិដកលេខ ១១ , ទំព័រ ២៦៦ ព្រះអានន្ទបានក្រាបទូលព្រះដ៏មានព្រះភាគថា « បពិត្រព្រះអង្គដ៏ចម្រើន ព្រះនាងមហាបជាបតិគោតមី មានឧបការៈច្រើន ជាព្រះមាតុច្ឆានៃព្រះមានព្រះភាគ ព្រះនាងបានទ្រាំទ្រ ថែរក្សា ថ្វាយទឹកក្សីរ [១] ក្នុងកាលដែលព្រះមាតាទ្រង់ព្រះទិវង្គតទៅ ព្រះនាងបានបំបៅព្រះអង្គតរៀងមក ។ បពិត្រព្រះអង្គដ៏ចម្រើន សូមទ្រង់ព្រះមេត្តាប្រោស ឱ្យមាតុគ្រាម [២] បានចេញចាកផ្ទះ ចូលមកកាន់ផ្នួសក្នុងធម្មវិន័យ ដែលព្រះតថាគតទ្រង់ជ្រាបច្បាស់ហើយផងចុះ » ។

១-ទឹកដោះស្រស់ ។

២-អ្នកដែលមានលំអានដូចជាមាតា-ស្ត្រី (ប្រែតាមវចនានុក្រម) ។

ក្នុងទំព័រដដែល ព្រះសម្មាសម្ពុទ្ធ ទ្រង់ត្រាស់ថា «ម្នាលអានន្ទ បើមាតុគ្រាមចេញចាកផ្ទះ ចូលមកកាន់ផ្នួសក្នុងធម្មវិន័យ ដែលតថាគតជ្រាបច្បាស់ហើយ ក៏អាចដើម្បីធ្វើឱ្យជាក់ច្បាស់នូវសោតាបត្តិផលខ្លះ សកទាគាមិផលខ្លះ អនាគាមិផលខ្លះ អរហត្តផលខ្លះបាន » ។

ការណ៍ដែលព្រះអង្គពុំទាន់អនុញ្ញាត តាមសំណូមពររបស់ព្រះនាងមហាបជាបតិគោតមី និងព្រះអានន្ទ មិនមែនបានសេចក្តីថាភិក្ខុនីឥតប្រយោជន៍នោះឡើយ ព្រោះក្នុងព្រះពុទ្ធសាសនានៃព្រះពុទ្ធគ្រប់អង្គ សុទ្ធតែមានភិក្ខុនីតែនេះ ដើម្បីស្មារតីមិនប្រមាទរបស់ស្ត្រីទាំងឡាយដែលបានបួសហើយនោះ ឱ្យប្រាកដច្បាស់ក្នុងចិត្តថា « មិនមែនបានដោយងាយឡើយ » ទាំងដែលត្រូវទទួលយកគរុធម៌ ៨ ប្រការមករក្សាទុករហូតដល់អស់ជីវិត ដើម្បីប្រយោជន៍ធំក្នុងព្រះពុទ្ធសាសនាទៀតផង ។

ចំណុចសំខាន់មួយទៀត គឺការតាំងពុទ្ធបរិស័ទ ៤ ជំពូក គឺភិក្ខុ ១ ជំពូក, ភិក្ខុនី ១ ជំពូក, ឧបាសក ១ ជំពូក



និងឧបាសិកា ១ ជំពូក ។ នេះសម្តែងឱ្យឃើញថា មានទាំងស្ត្រី មានទាំងបុរស ក្នុងតួនាទីរួមគ្នារក្សាទ្រទ្រង់ព្រះពុទ្ធសាសនា ។ ដែលព្រះអង្គព្រមដាក់ព្រះជន្មាយុសង្ខារចំពោះមុខមារ ក៏ព្រោះព្រះអង្គទ្រង់ជ្រាបអំពីបរិស័ទទាំង ៤ ជំពូកនេះឯង ថាបានសិក្សាទ្រទ្រង់ព្រះធម៌ បដិបត្តិព្រះធម៌ សម្តែងព្រះធម៌ និងអាចដោះស្រាយចំពោះវាទៈផ្សេងៗបាន ធ្វើឱ្យសាសនាបរិសុទ្ធប្រាសចាកមន្ទិល[១] ។

សេចក្តីទាំងអស់នេះឯង ដែលបញ្ជាក់ឱ្យដឹងថា ព្រះពុទ្ធសាសនា ឱ្យសិទ្ធិដល់ស្ត្រី និងបុរសស្មើគ្នាយ៉ាងពិតប្រាកដ ក្នុងការដែលត្រូវសិក្សាព្រះធម៌ បដិបត្តិព្រះធម៌ សម្តែងព្រះធម៌ រក្សាព្រះសាសនា ទាំងក្នុងកិច្ចការទំនុកបម្រុងវត្តអារាម ដោះស្រាយបញ្ហាផ្សេងៗ ។ល។

១.មើលក្នុងបិដកលេខ ១៦ ក្នុងមហាបរិនិព្វានសូត្រ ។

## ២.បែបបទនិងតួនាទី

ក្នុងព្រះពុទ្ធសាសនានេះ ស្ត្រីនិងបុរសមានបែបបទនិងតួនាទីផ្សេងគ្នា ។ ការផ្សេងគ្នានេះ បានប្រាកដយ៉ាងច្បាស់ក្នុងកិច្ចការតួនាទីជាអ្នកគ្រប់គ្រងផ្ទះ ។

ព្រះសម្មាសម្ពុទ្ធ ព្រះអង្គទ្រង់បានណែនាំដល់តួនាទីនិងបែបបទរបស់ស្ត្រី ក្នុងឋានៈជាភរិយាដែលគប្បីបដិបត្តិចំពោះស្វាមី មាន ៥ ប្រការ [១] :

១.ចាត់ចែងការងារផ្ទះឱ្យបានរៀបរយ ។

២.សង្គ្រោះញាតិមិត្តទាំងពីរខាង (ខាងខ្លួនឯងនិងខាងស្វាមី) ។

៣.មិនប្រព្រឹត្តក្បត់ចិត្តស្វាមី ។

៤.រក្សាទ្រព្យសម្បត្តិដែលស្វាមីរកមកបាន ។

៥.ព្យាយាមមិនខ្ជិលច្រអូសក្នុងការងារទាំងពួង ។

១.បិដកលេខ ១៩ ក្នុងសិង្គាលកសូត្រ



ទាំងនេះព្រោះព្រះអង្គទ្រង់ជ្រាបច្បាស់ថា សេចក្តីសុខសាន្តក្នុងការព្រមព្រៀងគ្នា នៅក្នុងសង្គមគ្រួសារនោះដោយច្រើននិងជាការសំខាន់គឺនៅលើស្ត្រី ។ ព្រះអង្គក៏ពុំបានសម្តែងតួនាទី និងបែបបទ ចំពោះតែស្ត្រីប៉ុណ្ណោះឡើយ សូម្បីតួនាទី និងបែបបទរបស់បុរសក្នុងឋានៈជាស្វាមី ដែលគប្បីបដិបត្តិចំពោះភរិយា ព្រះអង្គក៏បានត្រាស់សម្តែងទុកដោយគោល ៥ ប្រការផងដែរ [១] :

១.រាប់អាននាង ឱ្យតម្លៃនិងលើកតម្កើងនាង ថាជាភរិយាពេញមុខ ។

២.មិនមើលងាយនាងដែលជាភរិយាឡើយ ។

៣.មិនប្រព្រឹត្តក្បត់ចិត្តភរិយា ។

៤.ប្រគល់ភាពជាធំឱ្យដល់នាងក្នុងការងារផ្ទះ ។

៥.រកគ្រឿងប្រដាប់កាយឱ្យភរិយាតាមឱកាស ។

យើងឃើញបានថា ព្រះពុទ្ធសាសនាមិនបានឱ្យសេចក្តីសំខាន់ ចំពោះតែបែបបទនិងតួនាទីរបស់បុរស

១.បិដកលេខ ១៩ ក្នុងសិង្គាលកសូត្រ

ប៉ុណ្ណោះឡើយ ស្ត្រីក៏មានបែបបទនិងតួនាទីដ៏យ៉ាងសំខាន់ណាស់ដែរ បែបបទនិងតួនាទីទាំងពីរផ្នែកនេះ ចូលគ្នាហើយ ក៏បានបង្កើតចេញនូវភាពសុខសាន្តជាសុភមង្គលក្នុងជីវិតគ្រួសារ ។

ពោលដោយសរុប ព្រះពុទ្ធសាសនាបានរៀបចំស្ត្រីនិងបុរសឱ្យមានតួនាទី និងបែបបទផ្សេងគ្នា ទៅតាមច្បាប់ធម្មជាតិ ដូចជា ស្ត្រីមានតួនាទី និងបែបបទក្នុងការងារជាភរិយានិងជាមាតា ព្រមទាំងជាឧបាសិកាផង ។ ក្នុងពេលជាមួយគ្នា បុរសក៏មានតួនាទីនិងបែបបទក្នុងការងារជាស្វាមី ជាបិតា និងជាឧបាសកផងដែរ ។ ទាំងស្ត្រី ទាំងបុរស សុទ្ធតែអាចបំពេញនូវប្រយោជន៍ឱ្យដល់សង្គមគ្រួសារ ព្រះសាសនា និងប្រទេសជាតិបានដូចគ្នា ។

សភាពផ្សេងគ្នានៃតួនាទីនិងបែបបទរបស់ស្ត្រីនោះមានទំនាក់ទំនងទៅតាមធម្មជាតិ របស់បុរសស្ត្រីហ្នឹងឯង ប៉ុន្តែ អ្វីដែលព្រះពុទ្ធសាសនាបញ្ជាក់ប្រាប់ថាដូចគ្នានោះគឺការបានសម្រេចនូវធម៌ដ៏ខ្ពង់ខ្ពស់និងភាពជាមនុស្ស ។



ព្រះពុទ្ធសាសនា ជាសាសនានៃបញ្ញា មានមេត្តាករុណា និងណែនាំឱ្យមនុស្សមានការអើពើជួយដល់គ្នានឹងគ្នា មិនបែងចែកវណ្ណៈក្នុងរឿងភេទស្រីប្រុសឡើយ ។ ព្រះពុទ្ធសាសនា បានបើកទូលាយឱ្យមនុស្សគ្រប់គ្នាអប់រំចម្រើននូវគុណធម៌ អភិវឌ្ឍសមត្ថភាពរបស់ខ្លួន ឈានទៅរកទិសដៅដ៏ខ្ពង់ខ្ពស់ដែលជាខ្លឹមសារនៃជីវិត នោះគឺភាពជាឥស្សរៈផុតចាកពីទាសៈរបស់កិលេសទាំងឡាយ ។

សារសំខាន់មួយបែបក្នុងព្រះពុទ្ធសាសនា គឺបដិសេធន៍នូវអំពើហិង្សា ។ ដូចមាននៅក្នុងឱវាទប្បាតិ-មោក្ខក្នុងចំណុចមួយថា «បុគ្គលដែលបៀតបៀនអ្នកដទៃមិនមែនជាសមណៈទេ សម្លាប់សត្វដទៃមិនមែនជាបព្វជិតឡើយ [១] » ។ យើងឃើញថាព្រះពុទ្ធសាសនាមិនគាំទ្រមិនសរសើរ មិនលើកតម្កើងនូវបុគ្គលដែលប្រើអំពើហិង្សាជាដាច់ខាត ព្រោះថា នេះមិនមែនជាបព្វជិត និងមិនមែនជាសមណសក្យបុត្តិយ៍ឡើយ។ ជាមួយគ្នានឹងរឿងនេះដែរ

---

១-ធម្មបទ ពុទ្ធវគ្គ អានន្ទត្ថេរប្បញ្ហា

យើងបែរទៅពិនិត្យមើល លម្អនៃពាក្យទូន្មានរបស់ព្រះពុទ្ធ ទាក់ទងនឹងតួនាទីរបស់ស្វាមី ដែលត្រូវបដិបត្តិចំពោះ ភរិយារបស់ខ្លួន មាន ៥ ប្រការតាមដូចដែលបានពោល ហើយ ។

ការណ៍ដែលព្រះពុទ្ធបានចែកតួនាទី ឱ្យស្វាមីទំនុក-បម្រុងភរិយាដោយធម៌ ៥ ប្រការនេះ ដើម្បីជាប្រយោជន៍ គួរឱ្យយើងយល់បានគឺ

ចំណុចទី ១,ទី ២ និងទី ៣ ជាការថ្នមចិត្តស្ត្រីជា ភរិយា ដោយការលើកតម្កើងថា ជាភរិយាពេញមុខ មិន ប្រទូសរ៉ាយទឹកចិត្តរបស់នាងឡើយ។ ឯការមិនមើលងាយ វាអាចទាក់ទងទៅនឹងរូបរាង មុខមាត់ ឬក៏ការខ្វះខាត ដោយប្រការខ្លះរបស់នាង ដោយយកមេត្តាករុណា និង គុណធម៌ដទៃទៀតមកជំនួសសេចក្តីស្រឡាញ់ស្នេហាដែល ចុះខ្សោយទៅនោះ ព្រោះថា ការមិនមើលងាយ គឺជា ទេវតារក្សាជីវិតនាង ។ ការស្មោះស្ម័គ្ររបស់ស្វាមី ជា សេចក្តីសុខរបស់ភរិយា ជាការប្រោះព្រំនូវទឹកអម្រឹតដល់



បេះដូងនិងដើមទ្រូងនាង មិនឱ្យក្តៅងំដូចជាដុំរងើកភ្លើង នោះឯង ។

ចំណុចទី ៤ ជាការបែងចែកតួនាទី ឱ្យភរិយា ប្រគល់ភាពជាធំក្នុងផ្ទះ ឱ្យទទួលខុសត្រូវក្នុងការងារល្អិត-ល្អន់ ចាប់ផ្តើមតាំងពីថែរក្សាទុកដាក់ទ្រព្យសម្បត្តិ គ្រប់-គ្រងកូនប្រុសស្រីជាដើមទៅ (ពោលចំពោះតែភរិយានៅ ផ្ទះ ឯប្តីចេញទៅរកទ្រព្យប៉ុណ្ណោះ) ។

ចំណុចទី ៥ ជាការឱ្យកម្លាំងចិត្តដល់ភរិយា គឺឱ្យ ភរិយាបាននូវគ្រឿងប្រដាប់កាយ តែងខ្លួនតាមសមគួរដល់ ឋានៈ ។ នេះជាការថែរក្សាទំនុកបម្រុងទឹកចិត្តរបស់នាង និងដើម្បីសេចក្តីសុខក្នុងការគ្រប់គ្រងផ្ទះទាំងអស់គ្នា ។

ដែលស្វាមីថ្នមចិត្តភរិយា ប្រគល់ភាពជាធំក្នុងផ្ទះ និងទំនុកបម្រុងទឹកចិត្ត ដូចដែលពោលហើយនេះឱ្យដល់ ភរិយាទៅបាននោះ ក៏ព្រោះហេតុតែភរិយាបានបដិបត្តិ តួនាទីរបស់ខ្លួន ឆ្លើយតបទៅស្វាមី ក្នុងភាពជាស្រីល្អ គឺល្អ ទៅដោយបញ្ញាឆ្លាតវៃ ទឹកចិត្តទូលាយចេះសង្គ្រោះញាតិ

ស្មោះត្រង់ អត់ធន់ទទួលភារកិច្ច និងល្អទៅដោយឧស្សាហ៍ ខ្មីឃ្មាត ជាតួនាទីតាមលំដាប់លំដោយពី ១ ដល់ ៥ ។

តួនាទី និងបែបបទរបស់ភរិយាស្វាមី មានសេចក្ដីឆ្លើយឆ្លងគ្នាទៅវិញទៅមក តាមលំដាប់មួយៗ ។ ប៉ុន្តែបើសង្គ្រោះចូលក្នុងសារធម៌ គឺតួនាទីស្វាមីមានខ្លឹមសារនៅត្រឹមមេត្តាចិត្ត ប្រាសចាកអំពើហិង្សា ។ ឯតួនាទីភរិយាមានខ្លឹមសារនៅត្រង់ចរិយាធម៌ទាំង៥ ហ្នឹងឯងគឺបញ្ញា១, សង្គ្រោះ ១, សច្ចៈ ១ , ខន្តី ១ , វីរិយៈ ១ ។

ព្រះពុទ្ធសាសនា បានសាបព្រោះនូវគុណធម៌ ឱ្យដុះដាលក្នុងមនុស្សគ្រប់គ្នា តាមការសម្ដែងប្រាប់ពីតួនាទីនៃមនុស្សទាំងអស់ គ្រប់ភេទ គ្រប់វ័យ និងគ្រប់ឋានៈនោះឯង[១] ។ ការបណ្ដុះបណ្ដាលគុណធម៌ក្នុងខ្លួន គឺជាការសាងសិរីសួស្តីឱ្យខ្លួនឯង និងជាឧបនិស្ស័យល្អតទៅរហូត។ មនុស្សដោយច្រើន មិនយល់ពីតម្លៃនៃគុណធម៌ដែលត្រូវចម្រើនក្នុងខ្លួន យល់បានត្រឹមតែថា យើងធ្វើល្អឱ្យដល់អ្នក

១_បិដកលេខ ១៩ សិង្គាលកសូត្រ ។



ដទៃប៉ុណ្ណោះ។ ម្យ៉ាងទៀត យល់ខុសថា វាជាការអន់ថយក្នុងគុណគឺការគោរព សំពះ ថ្វាយបង្គំ បម្រើ អត់ធន់ជាដើមទៀតផង ។ តាមពិតគុណធម៌ធ្វើឱ្យជីវិតមានតម្លៃ សូម្បីតែគុណធម៌ទាំងឡាយនោះៗមានក្នុងទាសកម្មករ អ្នកបម្រើគេយ៉ាងណាក៏ដោយ គុណធម៌នៅតែជាឧបនិស្ស័យល្អក្នុងចិត្តជានិច្ច ។ មានតែបាបធម៌ទេ ដែលធ្វើឱ្យមនុស្សថោកទាប ។

តាមដែលពោលមកហើយនេះ អត្ថន័យសំខាន់ គឺនៅត្រង់ដែលថា ព្រះពុទ្ធសាសនា មិនគាំទ្រឱ្យបុរសប្រើកម្លាំងគ្របសង្កត់ចំពោះស្ត្រី ហើយប្រព្រឹត្តអំពើមិនគួរគប្បីអ្វីមួយឡើយ ទាំងកាយ ទាំងវាចា ទាំងចិត្ត ។ ផ្ទុយមកវិញ ព្រះពុទ្ធសាសនា ត្រឡប់បែរជាឱ្យបុរស ឬស្វាមីបដិបត្តិតួនាទីរបស់ខ្លួនឱ្យគ្រប់គ្រាន់ក្នុងបែបបទតួនាទីទាំង ៥ ប្រការ ។ ព្រះពុទ្ធសាសនាអប់រំឱ្យមនុស្សមានមេត្តាដល់គ្នា ដោយមានប្រធាននៃឱវាទ គឺសន្តិភាព ភ្លឺស្វាង ប្រាស-ចាកកិលេសតណ្ហា មិនមានការបៀតបៀនសត្វលោក ។

## ៣-បញ្ហាបែកបាក់គ្នា

ប្រសិនបើស្វាមីលះបង់ភរិយា ទៅមានស្ត្រីដទៃ ឬក៏ស្វាមីវាយតប់ភរិយា តើភរិយាត្រូវលះបង់ស្វាមី ឬក៏ត្រូវអត់ទ្រាំនៅតទៅទៀតទើបជាការល្អ ?

ការមិនស្មោះត្រង់ដល់គ្នារបស់ភរិយាស្វាមី ឬការប្រើកម្លាំងបាយ ប្រព្រឹត្តអំពើហិង្សាដើម្បីដោះស្រាយបញ្ហាក្នុងរឿងអ្វីនោះ ព្រះពុទ្ធសាសនាមិនប្រាថ្នាឱ្យកើតមានឡើយ ព្រោះស្ថាប័នគ្រួសារនីមួយៗ គឺជាស្ថាប័នរបស់សង្គមទាំងមូល ដែលសាងភាពរឹងមាំឱ្យដល់សង្គមជាតិហ្នឹងឯង ។ កាលបើស្ថាប័នគ្រួសារត្រូវបែកបាក់ រមែងមានផល ប៉ះខ្ទប់ទៅដល់សង្គមក្នុងផ្នែកដទៃទៀតផងដែរ ដោយចំពោះ កូនដែលកើតមកក្នុងសភាពគ្រួសារមានការបែកបាក់ នឹងទៅជាក្មេងដែលខ្វះភាពកក់ក្ដៅ និងនាំឱ្យមានបញ្ហាផ្សេងទៀត ។



ព្រះពុទ្ធសាសនា មានការគិតគូរក្នុងរឿងនេះណាស់ ដូចដែលបានឃើញគោលធម៌សន្ទឹកសន្ធាប់ក្នុងព្រះត្រៃបិដក អប់រំណែនាំទាក់ទងក្នុងរឿងគ្រប់គ្រងផ្ទះ ។ សូម្បីតែរឿងជ្រើសរើសមនុស្សមកជាគូជីវិត ព្រះសម្មាសម្ពុទ្ធក៏បានណែនាំ ឱ្យតាំងនៅក្នុងគោលធម៌ដ៏ប្រពៃ ៤ យ៉ាងផងដែរ ដូចមានសេចក្ដីក្នុងបិដកលេខ ៤២ ,ទំព័រ ១៥១ សមជីវិសូត្រ នកុលបិតាបានក្រាបទូលព្រះដ៏មានព្រះភាគថា «បពិត្រព្រះអង្គដ៏ចម្រើន ចាប់ដើមតាំងតែពីខ្ញុំព្រះអង្គ បានប្រសព្វគ្នានឹងនកុលមាតា តាំងពីកំលោះក្រមុំមក មិនដែលប្រព្រឹត្តកន្លងចិត្តនៃនកុលមាតា សូម្បីដោយចិត្តម្ដងឡើយ មិនបាច់ពោលថ្វីដល់ទៅការធ្វើដោយកាយនោះទេ ។ បពិត្រព្រះអង្គដ៏ចម្រើន យើងខ្ញុំព្រះអង្គប្រាថ្នាឱ្យជួបគ្នាក្នុងបច្ចុប្បន្ននេះផង ឱ្យជួបគ្នាក្នុងបរលោកផង »។ ចំណែកនកុលមាតា ក៏បានក្រាបទូលព្រះដ៏មានព្រះភាគ មានទំនងដូចគ្នាដែរ ។

ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា «បើជនទាំងពីរ

នាក់ប្ដីប្រពន្ធ ប្រាថ្នាឱ្យជួបគ្នាក្នុងបច្ចុប្បន្ននេះផង ឱ្យជួបគ្នាក្នុងបរលោកផង លុះតែជនទាំងពីរនាក់នោះ មានសទ្ធាស្មើគ្នា មានសីលស្មើគ្នា មានចាគៈស្មើគ្នា និងមានបញ្ញាស្មើគ្នា » ។ រួចហើយព្រះអង្គទ្រង់ត្រាស់ ៣ គាថាជាបន្តទៀត ដែលមានសេចក្ដីប្រែដូចតទៅ :

ជនទាំងពីរនាក់ ជាអ្នកមានសទ្ធា និងជាអ្នកដឹងពាក្យពេចន៍នៃស្មូម ជាអ្នកសង្រួមក្នុងសីល ចិញ្ចឹមជីវិតតាមគន្លងធម៌ ប្រពន្ធនិងប្ដីទាំងនោះ ពោលពាក្យផ្អែមល្ហែមរកគ្នានឹងគ្នា រមែងមានសេចក្ដីចម្រើនដ៏ច្រើន ទាំងមានការនៅជាសុខ កើតឡើងដល់គ្នានឹងគ្នា ។ ពួកសត្រូវរមែងអាក់អន់ចិត្តចំពោះជនទាំងពីរនាក់ ដែលមានសីលស្មើគ្នា លុះប្រព្រឹត្តធម៌ក្នុងលោកនេះហើយ បើមានចំណង់ក្នុងកាមក៏រមែងជាអ្នកត្រេកអររីករាយក្នុងទេវលោកបាន។

ក្នុងបិដកលេខ ៣០ និងលេខ ៥៤ មានព្រះសូត្រឈ្មោះ អាឡវកសូត្រ សេចក្ដីខាងចុង ព្រះអង្គទ្រង់សម្ដែងអំពីគោលធម៌ ៤ យ៉ាង សម្រាប់អ្នកគ្រប់គ្រងផ្ទះ និងធ្វើឱ្យ



ការគ្រប់គ្រងគូជីវិតពិតប្រសើរ ៤ យ៉ាងគឺ

១-**សច្ចៈ** ពិតត្រង់ដល់គ្នា គួរឱ្យសរសើរ ។

២-**ទមៈ** ការទូន្មានចិត្ត មានបញ្ញាក្នុងការរស់នៅ។

៣-**ខន្តិ** ព្យាយាមអត់ធន់ ចម្រើនទ្រព្យស្ងប់ជម្លោះ។

៤-**ចាគៈ** មានការបរិច្ចាគលះបង់ ឱ្យអភ័យ មានអធ្យាស្រ័យសន្ដោសប្រោសប្រណី មិនប្រកាន់ក្នុងរឿងរបស់សត្វលោក ... រមែងចងនូវមិត្តចិត្តសប្បុរស ។

ក្នុងបិដកលេខ ១៩ សិង្គាលកសូត្រ ក្នុងនោះព្រះអង្គទ្រង់សម្ដែងអំពីតួនាទីរបស់ស្វាមី ដែលត្រូវបដិបត្តិចំពោះភរិយា មាន ៥ ប្រការ :

១-រាប់អានឱ្យតម្លៃ និងលើកតម្កើងថាជាភរិយា ។

២-មិនមើលងាយមើលថោកភរិយា ។

៣-មិនប្រព្រឹត្តក្បត់ចិត្តភរិយា ។

៤-ឱ្យភាពជាធំក្នុងផ្ទះដល់ភរិយា ។

៥-ឱ្យគ្រឿងអលង្ការដល់ភរិយា ។

ចាកគោលធម៌ខ្លះៗ ក្នុងបណ្ដាគោលធម៌ដ៏ច្រើន

ទៀតមកបញ្ជាក់នេះ ជាការសម្តែងឱ្យឃើញដល់ការគិត-គូររបស់ព្រះពុទ្ធសាសនា ដែលមានចំពោះស្ថាប័នគ្រួសារ ក្នុងឋានៈជាស្ថាប័នឫសគល់របស់សង្គម។ ព្រះពុទ្ធសាសនា ត្រូវការឱ្យស្ថាប័នគ្រួសារមានភាពរឹងមាំ ។

សំណួរដែលថា បើស្វាមីលះបង់ភរិយា ទៅមានស្ត្រីដទៃ ឬវាយតប់ភរិយា តើភរិយាត្រូវសម្រេចចិត្តយ៉ាងណានោះ ក្នុងករណីនេះ ព្រះពុទ្ធសាសនាបានណែនាំគោលធម៌សព្វគ្រប់ សម្រាប់ទប់ស្កាត់ការពារកុំឱ្យកើតឡើង តែបើវាកើតឡើងហើយ នឹងធ្វើយ៉ាងណា ។ តាមពិតក្នុងរឿងនេះ ស្វាមីបានធ្វើខុសគោលធម៌ក្នុងព្រះពុទ្ធ-សាសនា ខុសសន្យាដែលបានយល់ព្រមរួមជីវិតគ្នា ខ្វះការគ្រប់គ្រងខ្លួនឯង មិនមាននូវកាមសំវរៈ (ការសង្រួមក្នុងកាម ) និងខ្វះនូវគោលធម៌មួយដ៏សំខាន់ គឺសទារសន្តោស (ត្រេកអរចំពោះតែភរិយារបស់ខ្លួន ) ។ ក្នុងសភាពបែបនេះ ភរិយាត្រូវបានទទួលការវាយប្រហារផ្លូវចិត្តដ៏ធ្ងន់ធ្ងរ ទាំងការក្បត់ចិត្ត ទាំងការវាយតប់ផ្លូវកាយ ។



ព្រះធម៌ក្នុងគម្ពីរព្រះពុទ្ធសាសនា មិនបានវែងឆ្ងាយទៅដល់ថ្នាក់ប្រាប់ការសម្រេចចិត្តយ៉ាងណា។ ឱ្យចំ។ នៅពេលភរិយាជួបបញ្ហាបែបនេះនោះឡើយ ។

ព្រះពុទ្ធសាសនា បានសម្តែងអំពីទុក្ខទោសនៃជីវិតមានច្រើនបែបច្រើនយ៉ាង ទោសរបស់កាមទាំងឡាយមានច្រើនក្រៃពេក កាមទាំងឡាយមានសេចក្តីសុខតិចមានទុក្ខច្រើន មានសេចក្តីចង្អៀតចង្អល់ច្រើន ។ល។

មិនមែនថា ព្រះពុទ្ធសាសនាខ្វះមធ្យោបាយជួយក្នុងរឿងនេះទេ ព្រះពុទ្ធសាសនាមានមាគ៌ានាំអ្នកបដិបត្តិទាំងឡាយទៅដល់ទីបំផុតទុក្ខ ឱ្យតែអ្នកបដិបត្តិទាំងនោះព្រមឃើញថា « កិលេសក្នុងខ្លួនជាសត្រូវពិតប្រាកដនឹងខ្លួនឯង »។ ចាកគោលធម៌ ៤ យ៉ាងសម្រាប់អ្នកគ្រប់គ្រងផ្ទះគឺ សច្ចៈ ទមៈ ខន្តិ ចាគៈ យើងនឹងជ្រាបបានថា កាលណាមានបញ្ហាកើតឡើងក្នុងគ្រួសារ ក្នុងលំដាប់ដែលមិនខ្លាំងក្លាពេក ព្រះពុទ្ធសាសនាឱ្យបដិបត្តិនូវវិធីអត់ធន់ទូន្មាន និងឱ្យអភ័យ ដើម្បីរកផ្លូវដោះស្រាយបញ្ហាដោយ

ប្រការផ្សេងៗ ។ ប៉ុន្តែបើករណីនោះឋិតនៅក្នុងលំដាប់ខ្លាំងក្លា រហូតដល់ថ្នាក់ដែលមិនអាចនិយាយឱ្យចុះសម្រុងគ្នាបាន ព្រះពុទ្ធសាសនាក៏ឱ្យសេរីភាពសម្រាប់ជ្រើសរើសជីវិតក្នុងការរស់នៅដែរ មិនមែនចេះតែឱ្យអត់ធន់ដូចគោដូចក្របីនោះឯណា ព្រោះថាមនុស្សម្នាក់ៗ ត្រូវមានបញ្ញាគូគ្នាជាមួយនឹងសេចក្ដីអត់ធន់ ហើយត្រូវចាំកុំភ្លេចថាសត្រូវពិតប្រាកដ គឺកិលេសក្នុងចិត្តរបស់ខ្លួនឯង ។

ក្នុងបិដកលេខ ៤៧ អព្យាកតវគ្គ ភរិយាសូត្រ ក្នុងនោះ ព្រះដ៏មានព្រះភាគទ្រង់សម្ដែងអំពីភរិយា ៧ ពួក គឺ ៣ ពួកមិនល្អ ចំណែក ៤ ពួកទៀតជាភរិយាល្អ ។ ភរិយាល្អ ៤ ពួកគឺ ១-ភរិយាល្អដូចមាតា , ២-ភរិយាល្អដូចបង ឬប្អូនស្រី , ៣-ភរិយាល្អដូចកល្យាណមិត្ត និង ៤-ភរិយាល្អដូចទាសី ។ យើងស្ដាប់ឮពាក្យថា «ដូចទាសី » ហាក់ដូចជាអន់ថយទន់ទាបណាស់ តាមពិត ផ្ទុយទៅវិញទេ ភរិយានៅតែជាភរិយា ហើយគឺជាភរិយាល្អណាស់ទៀតផង ព្រោះជាភរិយាដែលមានចិត្តមិនប្រទូស្តតបវិញ ចេះ



អត់ធន់ មិនខឹងក្រោធ ឱ្យអភ័យដល់ស្វាមី ក្នុងករណីដែលស្វាមីជេរ វាយ គំរាមដោយដំបង ។ ស្ត្រីដែលមានទេវធម៌ក្នុងខ្លួនដូច្នេះ ក្រោយពីស្លាប់នឹងបដិសន្ធិក្នុងទេវលោក ។ តាមពិត បុរសជាស្វាមីទើបថោកទាប ក្នុងអំពើសាហាវព្រៃផ្សៃ ជេរ វាយ គំរាមដោយដំបងប៉ងនឹងសម្លាប់ភរិយារបស់ខ្លួន ។ អំពើថោកទាបដូច្នេះ រមែងមិនមានក្នុងស្វាមីដែលជាកល្យាណបុថុជ្ជននិងសោតាបន្នបុគ្គលឡើយ ។

ក្នុងបិដកលេខ ៤២ , ទំព័រ ១៤១ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់សម្ដែងអំពីសង្វាស គឺការនៅរួមគ្នាជាមួយនិងស្វាមីភរិយា មាន ៤ យ៉ាង :

១-ខ្មោចប្រុសនៅរួមគ្នាជាមួយនឹងខ្មោចស្រី ។

២-ខ្មោចប្រុសនៅរួមគ្នាជាមួយនឹងទេវតាស្រី ។

៣-ទេវតាប្រុសនៅរួមគ្នាជាមួយនឹងខ្មោចស្រី ។

៤-ទេវតាប្រុសនៅរួមគ្នាជាមួយនឹងទេវតាស្រី ។

ដើម្បីឆ្លើយតបទៅនឹងសំណួរខាងដើម ខ្ញុំព្រះករុណា ខ្ញុំបាទសូមលើកយក ការនៅរួមគ្នានៃភរិយាស្វាមី

ក្នុងចំណុចទី ២ តាមព្រះពុទ្ធដីកា ដូចខាងក្រោមនេះ ។

ម្នាលគហបតីទាំងឡាយ ចុះខ្មោចប្រុសនៅរួមជាមួយនឹងទេវតាស្រី តើដូចម្តេច ។ ម្នាលគហបតីទាំងឡាយ ស្វាមីក្នុងលោកនេះ ជាអ្នកធ្វើបាណាតិបាត ធ្វើនូវអទិន្នាទាន ប្រព្រឹត្តនូវកាមេសុមិច្ឆាចារ ពោលពាក្យមុសា ក្រេបផឹកនូវទឹកស្រវឹង គឺសុរានិងមេរ័យដែលជាទីតាំងនៃសេចក្តីប្រមាទ ជាអ្នកទ្រុស្តសីល មានធម៌ដ៏លាមក មានចិត្តត្រូវមន្ទិលគឺសេចក្តីកំណាញ់រួបរឹត នៅគ្រប់គ្រងផ្ទះ ជាអ្នកជេរប្រទេចពួកសមណព្រាហ្មណ៍ ។ ប៉ុន្តែភរិយារបស់ស្វាមីនោះ ជាអ្នកវៀរចាកបាណាតិបាត វៀរចាកអទិន្នាទាន វៀរចាកកាមេសុមិច្ឆាចារ វៀរចាកមុសាវាទ វៀរចាកការក្រេបផឹកនូវទឹកស្រវឹងគឺសុរា និងមេរ័យ ដែលជាទីតាំងនៃសេចក្តីប្រមាទ ជាអ្នកមានសីលមានធម៌ល្អ មានចិត្តប្រាសចាកមន្ទិលគឺសេចក្តីកំណាញ់នៅគ្រប់គ្រងផ្ទះ ជាអ្នកមិនជេរប្រទេចពួកសមណព្រាហ្មណ៍។ ម្នាលគហបតីទាំងឡាយ យ៉ាងនេះឯង ឈ្មោះថាខ្មោច



ប្រុសនៅរួមគ្នាជាមួយនឹងទេវតាស្រី ។

ក្នុងការនៅរួមគ្នានេះ ព្រះពុទ្ធសាសនាត្រូវការឱ្យទេវតាប្រុសស្រីនៅរួមគ្នា ជាការសុខសាន្តទាំងក្នុងបច្ចុប្បន្នទាំងក្នុងបរលោក ។ ឯការរស់នៅជាមួយខ្មោចវិញ ត្រូវជួបទុក្ខលំបាកយ៉ាងណានោះ យើងអាចដឹងបានហើយ ។ ក្នុងព្រះពុទ្ធសាសនា មិនបានប្រាប់ថា ទេវតាបានជួបខ្មោចហើយ ត្រូវតែរស់នៅជាមួយខ្មោចរហូតទៅនោះឡើយ ផ្ទុយទៅវិញ ព្រះពុទ្ធសាសនា បានប្រាប់នូវហេតុដ៏អាក្រក់ក្រៃលែងក្នុងលោកនេះមានពីរយ៉ាង :

១-ហេតុដ៏អាក្រក់ក្រៃលែងខាងក្រៅគឺសេពគប់ជនពាល [១] ។

២-ហេតុដ៏អាក្រក់ក្រៃលែងខាងក្នុងគឺមិច្ឆាទិដ្ឋិ [២] ។

សរុបសេចក្តីមក តាមគោលព្រះពុទ្ធសាសនាគឺ

១-បើស្វាមីក្បត់ចិត្ត ក្បត់សន្យា ធ្វើខុសគោល-ការណ៍រួមជីវិតមួយនិងមួយ មិនមាននូវសេចក្តីសន្តោស

---

១-បិដកលេខ ៤០,ទំព័រ ៣៧ (មានបាបមិត្ត)។ ២-និយតមិច្ឆាទិដ្ឋិ។

ចំពោះភរិយារបស់ខ្លួន ទៅមានស្រីដទៃក្តី មានប្រពន្ធថែម ទៀតក្តី រឿងនេះវាស្រេចតែថា ភរិយាទទួលយកបានដែរ ឬទេ ទ្រាំបានដែរទេ បើទ្រាំនៅរួមតទៅទៀតដើម្បីអ្វី អាចមិនឆ្លងនូវរោគ ទាំងរោគផ្លូវកាយ ទាំងរោគផ្លូវចិត្ត (កិលេស) ដែរឬទេ ។ បើអាចទទួលយកបាន ទ្រាំបាន ឱ្យអភ័យបាន ដើម្បីកូននៅជួបជុំម៉ែឪ ចំណែកខ្លួនឯងក៏អាចនៅសាងបុណ្យកុសល ធ្វើទានរក្សាសីល សមាទានឧបោសថ ជាឧបនិស្ស័យល្អតទៅមុខបានផងដែរ ដូច្នេះចូរនៅធ្វើជាភរិយាល្អតទៅទៀតចុះ ។ ប៉ុន្តែបើហេតុការណ៍វាមានសភាពធ្ងន់ធ្ងរ ដល់ថ្នាក់ខ្លួនឯងមិនអាចទទួលយកបាន បើនៅរួមតទៅទៀតត្រូវស្លាប់ដោយការឆ្លងរោគ ឬស្លាប់ដោយការបៀតបៀន ការលបប្រហារពីប្រពន្ធក្រោយរបស់ប្តីជាដើម ពុំនោះសោត កុសលធម៌របស់ខ្លួនមានតែការសាបសូន្យ អកុសលធម៌មានតែការចម្រើនឡើងដូច្នេះព្រះពុទ្ធសាសនាឱ្យសេរីភាពក្នុងការជ្រើសរើសជីវិតរស់នៅ ឱ្យតែការរស់នៅមានសេចក្តីចម្រើន រួចផុត



ពីអន្តរាយគ្រប់យ៉ាង ។ នេះមិនមែនភរិយាខ្វះខាតនូវភាពស្មោះត្រង់នោះទេ ព្រោះល័ក្ខខ័ណ្ឌនៃភាពស្មោះត្រង់នោះត្រូវស្វាមីទម្លាយចោលទៅហើយ ។ ភរិយាត្រូវប្រព្រឹត្តទៅតាមផ្លូវច្បាប់ បែកចាកពីស្វាមីតាមផ្លូវច្បាប់ដោយសន្តិវិធី។ ក្នុងករណីនេះ ប្រសិនបើភរិយាត្រូវការបុរសដទៃជាស្វាមីទៀត ចាំបាច់ត្រូវតែឱ្យស្វាមីលែងលះខ្លួនជាមុនសិនហ្នឹង-ឯង បើពុំនោះទេ ភរិយាត្រូវទោសកាមេសុមិច្ឆាចារ (ទ្រុស្តសីល) ។

២-បើស្វាមីប្រើអំពើហិង្សា វាយតប់ ជេរប្រមាថស្រវឹងស្រារាល់ថ្ងៃ រំលោភលើរូបរាងកាយ ។ល។ រឿងនេះបើនៅមិនទាន់ខ្លាំងក្លាទេ នៅរកផ្លូវដោះស្រាយបានពួកញាតិក្តី អាជ្ញាធរក្តី អាចជួយនិយាយបាន ព្រះពុទ្ធ-សាសនាឱ្យប្រើគោលធម៌ខន្តី អត់ធន់ និងអប់រំទូន្មានចិត្តដោយបញ្ញា ព្រមដោយការឱ្យអភ័យ ។ ប៉ុន្តែ បើបញ្ហាខ្លាំងក្លារហូតដល់ថ្នាក់មិនអាចដោះស្រាយបាន ព្រះពុទ្ធ-សាសនាក៏ឱ្យសិទ្ធិសេរីភាពក្នុងការរស់នៅដូចគ្នាដែរ មិន

មែនទ្រាំនៅឱ្យប្ដីវាយស្លាប់ ហើយចាំទៅកើតឋានសួគ៌ ដោយចេះអត់ធន់នោះឡើយ ។

នៅក្នុងព្រះពុទ្ធសាសនា មានគោលធម៌សម្រាប់ធ្វើឱ្យមនុស្សល្អ គឺខន្តីពិតមែនហើយ ប៉ុន្តែជីវិតដែលរស់នៅប្រសើរ គឺរស់នៅប្រកបដោយបញ្ញា ។ ក្នុងបិដកលេខ ៣០,ទំព័រ ២៣២ ព្រះពុទ្ធទ្រង់ត្រាស់ថា « ពួកអ្នកប្រាជ្ញពោលថា បុគ្គលដែលរស់នៅដោយបញ្ញា ឈ្មោះថារស់នៅប្រសើរ » ។



## ៤-ជីវភាពស្ត្រីជាមួយនឹងព្រះពុទ្ធសាសនា

១-ស្ត្រីធ្វើការក្រៅផ្ទះ

២-ស្ត្រីមិនមានស្វាមី

៣-ស្ត្រីពេស្យាចារ

ក្នុងបែបបទតួនាទីរបស់ភរិយា ចំណុចទី ៤ គឺ **ភរិយាគប្បីរក្សាទ្រព្យសម្បត្តិដែលស្វាមីរកមកបាន** ក៏ដូចជាចំណុចទី ១ ដែលថា **ចាត់ចែងការងារផ្ទះឱ្យបានរៀបរយ** នេះបញ្ជាក់ថា ភរិយាធ្វើការក្នុងផ្ទះ ។ ប៉ុន្តែបើភរិយាមានការងារត្រូវទៅធ្វើក្រៅផ្ទះដែរ ដូចសព្វថ្ងៃនៅស្រុកខ្មែរយើងក៏មានមិនតិចឡើយ ដូច្នេះតើព្រះពុទ្ធសាសនាមានប្រតិកម្មយ៉ាងណា ឬក៏មានការណែនាំយ៉ាងដូចម្ដេច ? ឯចំណែកស្ត្រីក្រមុំក្មេង ក្រមុំចាស់ និងស្ត្រីមេម៉ាយជាមួយនឹងព្រះពុទ្ធសាសនា តើយ៉ាងណាដែរ ? ជាពិសេសស្ត្រីរកស៊ីផ្លូវភេទ (ពេស្យាចារ) តើព្រះពុទ្ធសាសនាមាន

ទស្សនៈយ៉ាងណា ?

## ដំណោះស្រាយ

### ១-ស្ត្រីធ្វើការក្រៅផ្ទះ

ព្រះពុទ្ធសាសនា កើតឡើងកណ្តាលសង្គមមនុស្ស ដែលមានទស្សនគតិ ជំនឿ ប្រពៃណី ការនិយម និងការបដិបត្តិទៅតាមលទ្ធិសាសនាដើមនោះៗ ។ ក្នុងសាសនាព្រាហ្មណ៍ប្រកាន់យកបុរសជាធំ ជាមនុស្សសំខាន់ ជាអ្នកដឹកនាំគ្រួសារ រមែងតែងតែចេញទៅប្រកបការងារអាជីពស្វែងរកទ្រព្យសម្បត្តិមកឧបត្ថម្ភក្រុមគ្រួសារ ចំណែកស្ត្រីរមែងជាអ្នកនៅថែរក្សាទ្រព្យសម្បត្តិ និងរបៀបរៀបរយក្នុងផ្ទះព្រមទាំងត្រូវគោរពប្រណិប័តន៍ស្វាមី បីដូចគោរពទេវតាទៀតផង ។

ព្រះពុទ្ធសាសនាក្នុងឋានៈជាស្ថាប័នមួយក្នុងសង្គម បានជ្រែកខ្លួនចូលមកក្នុងសង្គមមនុស្សសម័យនោះ មិនមែនជាស្ថាប័នផ្នែកខាងការគ្រប់គ្រង ដែលនឹងត្រូវមក



មើលថែក្នុងរឿងហូបចុករបស់ប្រជាជននោះឡើយ ។ ព្រះពុទ្ធសាសនា គឺជាស្ថាប័នផ្នែកសាសនា ដែលមានមុខងារខាងការអប់រំពន្យល់នូវព្រហ្មចរិយធម៌ ដើម្បីឱ្យដំណើរជីវិតបានប្រសើរឡើង ។ ដូច្នោះ ព្រះពុទ្ធសាសនាទើបមិនមានតួនាទីអ្វី ដែលនឹងត្រូវទៅកំណត់បែបបទរបស់ប្រជាជនថា ត្រូវប្រកបការងារអាជីពអ្វី ត្រូវធ្វើការងារកន្លែងណា ឬអ្នកណាត្រូវទៅធ្វើក្រៅផ្ទះ អ្នកណាត្រូវនៅក្នុងផ្ទះ យ៉ាងនេះជាដើមឡើយ ប៉ុន្តែព្រះពុទ្ធសាសនា បានអប់រំណែនាំឱ្យយល់នូវគោលធម៌ជាកណ្តាលៗ ដែលអាចនាំយកទៅបដិបត្តិបានគ្រប់ការងារអាជីព គ្រប់ស្ថានទី និងគ្រប់កាលសម័យ ដើម្បីឱ្យការងារនោះបានសម្រេចផលល្អត្រឹមត្រូវ ។

ចំណុចសំខាន់នៃព្រះពុទ្ធសាសនា ក្នុងបញ្ហាខាងលើនោះ គឺយើងត្រូវយល់ឱ្យច្បាស់ថា មិនមែនឋិតនៅត្រង់ មនុស្សធ្វើការកន្លែងណា ក្រៅផ្ទះ ឬក្នុងផ្ទះនោះទេ។ តាមការច្បាស់លាស់គឺនៅត្រង់ចំណុចដែលថា ធ្វើការ

យ៉ាងណាទើបបានជួបប្រសព្វនូវផលសម្រេច មានគោល-ធម៌អ្វីដែលត្រូវប្រកបក្នុងការងារនោះៗ ។ គប្បីជ្រាបថា បែបបទមនុស្សក្នុងសង្គម វាទៅតាមកាលសម័យនីមួយៗ មិនមែនសុទ្ធតែដូចគ្នានោះទេ ។ វានៅត្រង់ដែលថា មានហេតុមានបច្ច័យយ៉ាងណា សង្គមបរិយាកាសយ៉ាងម៉េច វប្បធម៌ អរិយធម៌ ទំនៀមទម្លាប់ ការនិយម ជំនឿ ប្រពៃណី ព្រមដោយស្ថានការណ៍ក្នុងសង្គម សេដ្ឋកិច្ច គ្រួសារ ។ល។ បើព្រះពុទ្ធសាសនា ទៅកំណត់ថា ស្ត្រី ឬ បុរសគួរធ្វើការងារត្រង់នេះ ឬត្រង់នោះ លុះដល់ក្រោយមក ការនិយមរបស់សង្គមត្រូវផ្លាស់ប្តូរ ដូច្នោះព្រះធម៌ក្នុងព្រះពុទ្ធសាសនាក៏ត្រូវហួសសម័យទៅផងដែរ ។ ព្រោះហេតុដូច្នេះឯង ទើបសេចក្តីដែលថា ស្ត្រីនឹងធ្វើការក្នុងផ្ទះ ឬក្រៅផ្ទះ មិនមែនជាចំណុចដែលព្រះពុទ្ធសាសនាកំណត់ឱ្យនោះឡើយ ព្រោះវាជារឿងទៅតាមជំនាន់កាល និងទៅតាមការនិយមរបស់សង្គម ។ ចំណុចសំខាន់នៃគោលធម៌ព្រះពុទ្ធសាសនា នៅត្រង់ដែលថា ធ្វើយ៉ាងណាឱ្យបាន



សម្រេចនូវប្រយោជន៍ ទោះជាការងារនោះក្នុងផ្ទះក៏ដោយ ក្រៅផ្ទះក៏ដោយ ។ ព្រះពុទ្ធសាសនាលើកតម្កើងសរសើរនូវអ្នកដែលប្រឹងប្រែងព្យាយាម អត់ធន់តស៊ូហើយឆ្លាតឈ្លាសក្នុងហេតុផលនៃកិច្ចការ ។

ដូចដែលពោលមកហើយថា ព្រះពុទ្ធសាសនា កើតឡើងកណ្តាលសង្គមមនុស្ស ដែលក្នុងសង្គមនោះគេឱ្យសេចក្តីសំខាន់ចំពោះបុរស រហូតមកដល់សព្វថ្ងៃនេះ ជាពិសេសប្រទេសឥណ្ឌា ។ នៅប្រទេសឥណ្ឌាសព្វថ្ងៃ យើងឃើញសុទ្ធតែបុរស ស្ទើរតែទាំងអស់ដែលប្រកបមុខរបររកទទួលទាន ។ ចំណែកស្ត្រីមានតួនាទីមើលថែផ្ទះសំបែង រៀបចំទុកដាក់ រក្សាកូនប្រុសស្រី និងមើលថែម៉ែឪខាងប្តីជាដើម ។ ការងារមើលថែមនុស្សក្នុងគ្រួសារ ទុកដាក់ទ្រព្យសម្បត្តិ ជាការងារដែលមានសេចក្តីសំខាន់មិនអន់ជាងការងារក្រៅផ្ទះឡើយ ។ កាលបើបែបបទរបស់មនុស្សក្នុងសង្គម ត្រូវបានរៀបចំយ៉ាងនេះជាស្រេចហើយនោះ ព្រះពុទ្ធសាសនាមិនមានសិទ្ធិអ្វីដែលត្រូវទៅដូរផ្លាស់

របៀបរបបគេយ៉ាងហ្នឹងឡើយ ។ អ្វីដែលអាចធ្វើបានក្នុងខណៈនោះ គឺបង្រៀនគោលធម៌ ដើម្បីឱ្យយកទៅបដិបត្តិក្នុងតួនាទីនោះៗ ឱ្យបានប្រសើរជាទីបំផុត តាមដែលអាចធ្វើទៅបាន ។

របៀបរបបក្នុងសង្គមបច្ចុប្បន្ន ទៅតាមប្រទេសបានដូរផ្លាស់ទៅតាមស្ថានការណ៍ក្នុងស្រុកនិងក្រៅស្រុក។ បុរសចេញទៅធ្វើការក្រៅផ្ទះតែឯង រមែងមិនគ្រប់គ្រាន់សម្រាប់ចិញ្ចឹមក្រុមគ្រួសារ ដូច្នេះរឿងចាំបាច់ខាងសេដ្ឋកិច្ច តម្រូវឱ្យស្ត្រីចេញទៅធ្វើការងារក្រៅផ្ទះផងដែរ ទាំងដែលស្ត្រីឥឡូវនេះ បាននូវឱកាសសិក្សាចេះដឹងច្រើន និងមានការកសាងខ្លួនឱ្យចម្រើនទៅគ្រប់ផ្នែក ដូច្នេះ ហើយទើបធ្វើឱ្យស្ត្រីបានប្រើប្រាស់នូវចំណេះដឹងរបស់ខ្លួនបម្រើសង្គមជាតិ កាន់តែបានទូលំទូលាយទៅច្រើន ។ ចំពោះព្រះពុទ្ធសាសនា មិនបានប្រឆាំងអ្វីចំពោះស្ត្រីដែលចេញទៅធ្វើការក្រៅផ្ទះនោះឡើយ ហើយក៏មិនបានឱ្យសេចក្តីសំខាន់អ្វីចំពោះតែបុរសនោះដែរ ។ ព្រះពុទ្ធ-



សាសនាបានសម្តែងគោលធម៌ សម្រាប់ទាំងអស់គ្នា ទាំងគ្រប់ការងារទាំងអស់ ដែលនាំឱ្យសម្រេចនូវប្រយោជន៍ ទោះជាធ្វើកន្លែងណាក៏ដោយ ពេលណាក៏ដោយ គឺគោលធម៌ឥទ្ធិបាទ ៤ :

(១)- ឆន្ទៈ = ពេញចិត្តក្នុងការងារ ។

(២)- វីរិយៈ = ព្យាយាមធ្វើ ។

(៣)- ចិត្តៈ = យកចិត្តទុកដាក់ ។

(៤)- វីមង្សា = ចេះពិចារណាហេតុផល ។

## ២ -ស្ត្រីមិនមានស្វាមី

ព្រះពុទ្ធសាសនា ឱ្យមនុស្សមានការជឿលើសមត្ថ-ភាពរបស់ខ្លួន ។ មនុស្សគ្រប់គ្នា អាចអភិវឌ្ឍខ្លួនឯងឱ្យសម្រេចដល់ទិសដៅដ៏ខ្ពង់ខ្ពស់បាន ដោយមិនចំពោះភេទវណ្ណៈ ជនជាតិ និងសភាពការណ៍នៃជីវិតយ៉ាងណាៗនោះឡើយ ឱ្យតែបានចូលមកសិក្សាក្នុងព្រះពុទ្ធសាសនា ដោយសទ្ធា និងបញ្ញា ព្រមដោយការតាំងចិត្តមាំមួន ។ ព្រះ-

ពុទ្ធសាសនា មិនបានរង្កៀសចំពោះបុគ្គលណា ដែលធ្លាប់មានប្រវត្តិមិនល្អពីមុនមកនោះឡើយ មានតែលួងលោមឱ្យកម្លាំងចិត្ត បើកឱកាសឱ្យកែខ្លួន និងកសាងខ្លួន ព្រោះថា ព្រះពុទ្ធសាសនាមានតួនាទីជួយសត្វលោកដែលមានទុក្ខ ។ មនុស្សគ្រប់គ្នាអាចជួយខ្លួនឯងបាន ឱ្យតែបានមកជួបនឹងព្រះពុទ្ធសាសនា សូម្បីកាលមុនជាបុគ្គលប្រមាទដូចយ៉ាងអង្គុលីមាល លុះដល់ក្រោយមកជាបុគ្គលមិនប្រមាទ ក៏រមែងជាអ្នកភ្លឺស្វាងក្នុងដំណើរជីវិត ស្ងប់ស្ងាត់ត្រជាក់ ដូចជាលោកនេះដែលភ្លឺស្វាងដោយព្រះចន្ទពេញបូណ៌មី ចេញផុតពីពពក ដូច្នោះដែរ ។

ក្នុងសម័យពុទ្ធកាល មានស្ត្រីយ៉ាងច្រើនចូលកាន់ព្រះពុទ្ធសាសនា ក្នុងនោះមានស្ត្រីដែលអត់ស្វាមីមិនតិចនាក់ឡើយ ។ ស្ត្រីខ្លះមិនយកស្វាមី ហើយចូលកាន់ផ្នួស ស្ត្រីខ្លះទៀតក៏មិនយកស្វាមីដែរ តែប្រព្រឹត្តព្រហ្មចរិយធម៌ក្នុងផ្ទះ និងស្ត្រីមេម៉ាយដោយប្រការផ្សេងៗ បានចូលមកកាន់ព្រះពុទ្ធសាសនា ហើយអាចទូន្មានខ្លួនឯងបានរហូត



ដល់ថ្នាក់លោកុត្តរ ផុតកង្វល់ពីរឿងលោកិយទៀតផង ។

ក្នុងបិដកលេខ ៧៦ ខេមាថេរិយាបទាន បានប្រាប់អំពីព្រះរាជធីតា ៧ អង្គរបស់ព្រះបាទកិកិ គ្រប់គ្រងនគរពារាណសី សម័យព្រះសម្មាសម្ពុទ្ធកស្សបៈ ។ ព្រះនាងខេមាបានសម្ដែងថា :

ក្នុងកាលនោះ ខ្ញុំម្ចាស់ជាធីតាច្បងរបស់ព្រះរាជា ខ្ញុំម្ចាស់មាននាមប្រាកដថា **សមណី** បានស្ដាប់ព្រះធម៌របស់ព្រះវិជិតមារហើយ ក៏ពេញចិត្តក្នុងបព្វជ្ជា ។ ដោយព្រះបិតា ទ្រង់មិនអនុញ្ញាតឱ្យដល់ខ្ញុំម្ចាស់ទាំងឡាយបានចូលកាន់ផ្នួស កាលដែលនៅក្នុងផ្ទះគ្រានោះ ពួកយើងខ្ញុំម្ចាស់ជារាជកញ្ញា មិនខ្ជិលច្រអូស ប្រព្រឹត្តព្រហ្មចរិយធម៌តាំងពីកុមារី ឋិតនៅក្នុងសុខសម្បត្តិពីរម៉ឺនឆ្នាំ ។

ព្រះរាជធីតាទាំង ៧ អង្គ សុទ្ធតែពេញចិត្តក្នុងការទំនុកបម្រុងព្រះពុទ្ធសាសនា ព្រះរាជធីតាទាំង ៧ នោះគឺ នាងសមណី ១ , នាងសមណគុត្តា ១ , នាងភិក្ខុនី ១ , នាងភិក្ខុទាសិកា ១ , នាងធម្មា ១ , នាងសុធម្មា ១ និង

នាងសង្ឃទាសិកាជាគម្រប់ ៧ ។ ព្រះរាជធីតាទាំង ៧អង្គ នោះ បានមកជាខ្ញុំម្ចាស់ខេមា ជាព្រះនាងឧប្បលវណ្ណា-ថេរី ជាព្រះនាងបដាចារាថេរី ជាព្រះនាងកុណ្ឌលកេសី-ថេរី ជាព្រះនាងកិសាគោតមីថេរី ជាព្រះនាងធម្មទិន្នាថេរី និងព្រះនាងវិសាខាឧបាសិកាជាគម្រប់ ៧ តាមលំដាប់ ។

នៅក្រុងកោសម្ពី នាងខុជ្ជុត្តរាឧបាសិកា មិនមានស្វាមី ជាស្រីគម ។ កាលដើមនាងជាស្រីបម្រើគេ ហើយលួចទ្រព្យគេជារឿយៗ ទៀតផង ។ ក្រោយមកបានស្តាប់ព្រះធម៌ដែលព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់សម្តែង ក៏បានសម្រេចនូវគុណធម៌ជាន់ខ្ពស់ មានការចេះដឹងច្រើន ។ ឧបាសិកាខុជ្ជុត្តរា បានសម្តែងព្រះធម៌ឱ្យដល់មនុស្សក្នុងព្រះរាជវាំងស្តាប់ ញ៉ាំងអ្នកស្តាប់រាប់រយនាក់ឱ្យបានសម្រេចមគ្គផល ។ នាងបានរួចផុតពីភាពនៃខ្លួនជាស្រីបម្រើ ហើយឋិតនៅក្នុងឋានៈជាអ្នកសម្តែងធម៌ក្នុងព្រះ-រាជវាំង គឺនាងចេញទៅស្តាប់ព្រះធម៌ដែលព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់សម្តែងក្នុងក្រុងកោសម្ពី ហើយនាំយកមក



សម្តែងក្នុងព្រះរាជវាំង មាន ១១២ សូត្រក្នុងបិដកលេខ ៥៣ ដែលសុទ្ធតែមានសេចក្តីផ្តើមទាំងអស់ថា «ខ្ញុំបានស្តាប់មកថា ព្រះមានព្រះភាគ ទ្រង់ត្រាស់ហើយ ព្រះ-អរហន្តសម្តែងហើយ » ។ សូម្បីព្រះអានន្ទនាំយកមកកាន់សង្គាយនា ក៏មិនដូរសេចក្តីផ្តើមមកជា « **ឯវម្មេ សុតំ** ... » ដូចព្រះសូត្រផ្សេងៗ មានព្រះធម្មចក្កប្បវត្តន-សូត្រជាដើមឡើយ រមែងរក្សាសេចក្តីផ្តើមនោះទុក ដែលមានបាលីថា «**វុត្តំ ហេតំ ភគវតា វុត្តមរហតាតិ មេ សុតំ**» គ្រប់ទាំង ១១២ សូត្រ គឺឯកនិបាត ២៧ សូត្រ ទុកនិបាត ២២ សូត្រ តិកនិបាត ៥០ សូត្រ និង ចតុក្កនិបាត ១៣ សូត្រ ។ នាងខុជ្ជុត្តរាឧបាសិកា មានឧបការៈដ៏ក្រៃលែងក្នុងព្រះពុទ្ធសាសនា ព្រះសម្មាសម្ពុទ្ធបានត្រាស់សម្តែងតែងតាំងជាស្ត្រីគំរូទៀតផង [១] ។ មានស្ត្រីឯទៀតច្រើនណាស់ ដែលមិនមានស្វាមី ហើយជាស្ត្រីដែលអាចពឹងខ្លួនឯងបានយ៉ាងសុខសាន្ត រស់នៅក្នុងពន្ លី

---

១_បិដកលេខ ៤០ , ទំព័រ ១៩៩ ។

ព្រះធម៌ ។

ចំពោះស្ត្រីមេម៉ាយសន្ធឹកសន្ធាប់ កាលដែលបានចូលកាន់ព្រះពុទ្ធសាសនា ក៏អាចអប់រំខ្លួនឯងបានរហូតដល់ថ្នាក់ខ្ពង់ខ្ពស់ ដូចជា ព្រះនាងមហាបជាបតិគោតមី ព្រះនាងបដាចារាថេរី ព្រះនាងយសោធរា រាហុលមាតា និងព្រះនាងសិគាលមាតាថេរីជាដើម ។

ក្នុងបិដកលេខ ៤៧ , ទំព័រ ១១៦ មាតាសូត្រ បានសម្តែងពីនន្ទមាតាឧបាសិកា ជាព្រះអរិយបុគ្គលថ្នាក់អនាគាមី បានសូត្រធម៌នៅពេលជិតភ្លឺ ប្រមាណ ២៥០ គាថា ក្នុងបារាយនវគ្គ [១] ដោយសំឡេងដ៏ពីរោះ ។

ក្នុងកាលនោះ ទេវរាជ ព្រះនាមវេស្សវណ្ណ បានអនុមោទនាចំពោះការស្វាធ្យាយព្រះធម៌ របស់នន្ទមាតាឧបាសិកា [២] ។ ព្រះអដ្ឋកថា បានបញ្ជាក់សេចក្តីនៃការអនុមោទនារបស់ទេវរាជថា : សាធុ ! សាធុ ! បងស្រី

១-បារាយនវគ្គក្នុងបិដកលេខ ៥៤ , ទំព័រ ៣២៥ ដល់ទំព័រ ៣៧៦ ។

២-មិនមែនសូធ្យស្វាធ្យាយហើយ ទេវតាចេះតែអនុមោទនាទៅនោះទេ ទាល់តែ អ្នកសូធ្យធម៌នោះឯងសម្បូណ៌ដោយគុណធម៌ក្នុងខ្លួនទៀតផង ។



ព្រះធម៌ទេសនាដែលបងស្រីបានទទួលមកល្អណាស់ ទាំងដែលបានស្វាធ្យាយដោយល្អទៀតផង ខ្ញុំមិនបានឃើញថាមានការប្លែកគ្នាអ្វី អំពីថ្ងៃដែលព្រះសម្មាសម្ពុទ្ធ ទ្រង់គង់ប្រថាប់នៅបាសាណកចេតិយ ត្រាស់សម្តែងដល់បារាយនិកព្រាហ្មណ៍ទាំង ១៦ នាក់នោះឡើយ ។ បងស្រីសូធ្យថ្ងៃនេះ ដូចជាព្រះតម្រាស់របស់ព្រះសាស្តាដែលព្រះអង្គទ្រង់ត្រាស់ហើយនោះឯង ។

ស្តេចវេស្សវណ្ណជាព្រះសោតាបន្ន មានព្រះជន្ម ៩ លានឆ្នាំមនុស្ស ប៉ុន្តែហៅនន្ទមាតាឧបាសិកាថា បងស្រី ព្រោះនន្ទមាតាឧបាសិកា បងដោយគុណធម៌នោះឯង ។

នន្ទមាតាឧបាសិកា ជាស្ត្រីមេម៉ាយ កូនឈ្មោះនន្ទក៏ត្រូវគេសម្លាប់ ។ ដោយសារបានជួបនឹងព្រះពុទ្ធសាសនា វេឡុកណ្តកិយានន្ទមាតាក៏បានជាស្ត្រីគំរូ ដែលព្រះបរមសាស្តាទ្រង់តែងតាំង ជាមួយគ្នានឹងឧបាសិកាខុជ្ជុត្តរា ។ ដែលបានជាស្ត្រីគំរូ ក៏ព្រោះជាអរិយសាវិកាទ្រទ្រង់នូវព្រះពុទ្ធវចនៈ ជាពហុស្សូត ជួយគ្នាដើម្បីបន្តអាយុ

ព្រះពុទ្ធសាសនាហ្នឹងឯង ។

## ៣-ស្ត្រីពេស្យាចារ

ព្រះពុទ្ធសាសនា បានពន្យល់ប្រាប់ឱ្យមនុស្សជឿលើសមត្ថភាពរបស់ខ្លួន ។ ដរាបណានៅមានខ្យល់ដង្ហើមដរាបនោះ នៅតែមានឱកាសកសាងខ្លួន ។ ប្រភពនៃបញ្ហាក្នុងជីវិត វាឋិតនៅក្នុងចិត្តនៃមនុស្សម្នាក់ៗខ្លួនឯង ព្រោះចិត្តត្រូវហ៊ុមព័ទ្ធទៅដោយអវិជ្ជា ។

ព្រះពុទ្ធសាសនា បើកឱកាសឱ្យមនុស្សចូលមកសិក្សាបដិបត្តិ ដោយមិនរង្កៀសថា ប្រវត្តិដើមនោះសៅហ្មងយ៉ាងណាឡើយ ។ នាងអម្ពបាលី ស្រីសោភិនីប្រចាំនគរវេសាលី បានភ្ញាក់ខ្លួនទាន់ពេល វេរចម្ការស្វាយរបស់ខ្លួនឱ្យទៅជាសង្ឃារាម ចំណែកខ្លួនឯងក៏បានចូលកាន់ផ្នួស ហើយសម្រេចនូវព្រះអរហត្ត ផុតចាកពីកិលេស ដែលជាគ្រឿងសៅហ្មងគ្រប់យ៉ាង ។ នាងសិរិមា ជាសោភិនីប្រចាំក្រុងរាជគ្រឹះ ព្រមដោយបរិវាររាប់រយនាក់ បានជួប



នឹងព្រះសម្មាសម្ពុទ្ធ ស្តាប់ព្រះធម៌សម្រេចជាឧបាសិកាដល់នូវព្រះរតនត្រ័យជាទីពឹងទីរលឹក ព្រមដោយធម្មចក្ខុមានភ្នែកឃើញអរិយសច្ចធម៌ ។

ក្នុងលោកសន្និវាស ងងឹតដោយអវិជ្ជា សត្វលោកគ្រប់គ្នា ខ្វាយខ្វល់ព្រោះតែកិលេសរបស់ខ្លួនឯង មិនមាននរណាជួយបានក្រៅអំពីព្រះតថាគតឡើយ ដូច្នេះចូរគ្រប់គ្នាមកទទួលយកពន្លឺព្រះធម៌ ដើម្បីបំភ្លឺផ្លូវក្នុងដំណើរជីវិតរបស់ខ្លួន ។

# ៥-សោភិនី

សោភិនី ប្រែថា ស្រីល្អ ប៉ុន្តែគេយកពាក្យ «សោ-ភិនី» នេះ មកជាឈ្មោះស្រីរកស៊ីផ្លូវភេទ ។

ក្នុងសម័យពុទ្ធកាល សោភិនីជាអាជីពមួយមុខនៃស្ត្រីសម័យនោះ មនុស្សទូទៅគេយល់ថាជាអាជីពសុចរិត។ បុរសទាំងឡាយ ពេញចិត្តនឹងការស្វែងរកសេចក្តីសុខសប្បាយពីកាមរស ត្រង់ឆ្ពោះនាងដែលជាសោភិនីជានិច្ច។ បុរសទាំងនោះ មានតាំងពីអ្នកតូច អ្នកធំ រហូតដល់ព្រះ-រាជា តែងតែស្វែងរកសោភិនីមកកម្សាន្តសព្វៗកាល ។

សោភិនីមានច្រើនលំដាប់ ច្រើនថ្នាក់ សោភិនីថ្នាក់លេខ ១ ត្រូវបានព្រះរាជាតែងតាំង ឱ្យជានគរសោភិនី ។ តំណែងនេះបានមកដោយការជ្រើសរើស ប្រកួតប្រជែងរូបសម្បត្តិ ទាំងចំណេះដឹង ទាំងសមត្ថភាពក្នុងផ្នែកសិល្បៈផ្សេងៗ ព្រមដោយសំឡេងពីរោះ ។ សោភិនីនេះ មាន



កិត្តិយសខ្ពង់ខ្ពស់ប្រចាំនគរ អ្នកដែលមកកម្សាន្តនឹងរូប សំឡេង ក្លិន រស សម្ផស្សរបស់នាង ត្រូវចំណាយ ១ ពាន់កហាបណៈ សម្រាប់ ១ ថ្ងៃ (១ ពាន់កហាបណៈ = មាសសុទ្ធ ៦០ តម្លឹង ) ។ តម្លៃកហាបណៈក្នុងកាលនោះ គឺ ២ កហាបណៈ អាចធ្វើបណីតភោជនប្រគេនដល់ភិក្ខុឆាន់បាន ៣ ទៅ ៤ អង្គ [១] ។

ដែនកាសីដែលមានទីក្រុងឈ្មោះពារាណសី យកសួយបាន ១ ថ្ងៃ ១ ពាន់កហាបណៈ ស្មើនឹងតម្លៃដែលគេកម្សាន្តសប្បាយជាមួយនាងអឌ្ឍកាសី ១ ថ្ងៃ ។ បុរសខ្លះមានត្រឹមតែ ៥០០ កហាបណៈ រួមអភិរម្យជាមួយនាងបានតែពេលថ្ងៃប៉ុណ្ណោះ ព្រោះហេតុដូច្នោះ ទើបនាងជាប់ឈ្មោះមកថា នាងអឌ្ឍកាសី[២] ។ក្រោយមកនាងពិចារណាឃើញរូបកាយមិនទៀង ទើបឧបសម្បទាក្នុងសំណាក់ភិក្ខុនីសង្ឃ ហើយបំណងទៅឧបសម្បទាអំពីភិក្ខុសង្ឃ ក្នុងនគរសាវត្ថីដែលព្រះដ៏មានព្រះភាគគង់ប្រថាប់នៅទីនោះ។

---

១-អដ្ឋកថាធម្មបទ រឿងនាងសិរិមាក្នុងជរាវគ្គ ។

២-អឌ្ឍកាសីថេរីគាថា បិដកលេខ ៥៧ និង អដ្ឋកថា ។

ក្នុងកាលនោះ ពួកអ្នកលេងចាំស្ទាក់ចាប់នាងតាមផ្លូវ នាងដឹងដំណឹងដូច្នេះហើយ ទើបអាក់ខាន ។ រឿងនេះជ្រាបដល់ព្រះដ៏មានព្រះភាគ ព្រះអង្គទ្រង់អនុញ្ញាតឧបសម្បទាដោយទូត ចំពោះសាមីខ្លួនមិនចាំបាច់ទៅឡើយ ។ ក្រោយមកព្រះនាងអឌ្ឍកាសីថេរី ក៏បានសម្រេចនូវព្រះអរហត្ត ។

សោភិនីមានតំណែងក្នុងរាជការ បានទទួលប្រាក់ខែប្រាក់ថ្ងៃអំពីរាជការ និងបានទទួលប្រាក់បន្ថែមពីបុរសនោះៗ ម្ល៉ោះហើយ សោភិនីសម័យនោះទើបសម្បូណ៌ទៅដោយមាសប្រាក់សម្បត្តិទ្រព្យ មានមុខមាត់ ផ្ទះសំបែងធំដុំ មានបរិវាររាប់រយនាក់ ព្រមទាំងអ្នកបម្រើឆ្វេងស្តាំទៀតផង ។

ព្រះពុទ្ធសាសនា មានការឱ្យស័ក្តិ ឱ្យសិទ្ធិ ឱ្យកិត្តិយស លើកតម្កើងឱ្យខ្ពស់ ចំពោះអ្នកដែលតាំងចិត្តប្រព្រឹត្តល្អ ព្រោះព្រះពុទ្ធសាសនាមានខ្លឹមសារសំខាន់នៅត្រង់ការប្រព្រឹត្តធម៌ ។

មានពេលមួយ ដែលព្រះសម្មាសម្ពុទ្ធ ទ្រង់យាង



ចេញពីក្រុងសាវត្ថី កាលនោះ មិនមានអ្នកដទៃណា ហ៊ានអារាធនាព្រះអង្គ ឱ្យនៅគង់នាក្រុងសាវត្ថី បន្តទៅទៀតឡើយ បានត្រឹមតែស្រងូតស្រងាត់ក្នុងចិត្ត ដោយនឹកអាល័យព្រះអង្គប៉ុណ្ណោះ ។ សេដ្ឋី ព្រះរាជា សុទ្ធតែមិនហ៊ានអារាធនា ប៉ុន្តែនាងទាសីម្នាក់ តាមទៅអារាធនាព្រះអង្គ ដោយសន្យាថាខ្លួននឹងដល់នូវព្រះពុទ្ធ ព្រះធម៌ព្រះសង្ឃជាទីពឹងទីរលឹក ហើយរក្សាសីលរហូតតទៅ ។ ព្រះដ៏មានព្រះភាគទ្រង់ទទួល សាធុ ! សាធុ ! ហើយទ្រង់យាងត្រឡប់មកជេតពនមហាវិហារវិញ [១] ។ ជាការអស្ចារ្យដ៏ក្រៃលែង ដែលព្រះអង្គទ្រង់ប្រទាននូវកិត្តិយសដល់ស្ត្រីម្នាក់ជាទាសីគេ ព្រោះព្រះអង្គទ្រង់គោរពក្នុងធម៌មានធម៌ជាទីគោរព ។ មហាជនក្នុងក្រុងភ្ញាក់ផ្អើលនិងត្រេកអរយ៉ាងខ្លាំង បានបូជាចំពោះនាងបុណ្ណាទាសីដោយកហាបណៈដ៏ច្រើន ។ ព្រះសាស្តាទ្រង់សម្តែងព្រះធម៌ក្នុងសមាគមនោះ ញ៉ាំងពពួកជនឱ្យផឹកទឹកអម្រឹតរាប់ម៉ឺននាក់ ហើយព្រះអង្គទ្រង់បានបញ្ជូនព្រះអគ្គសាវ័កទាំងពីរ ឱ្យ

១-អដ្ឋកថា មាតាសូត្រ ។

និមន្ត ទៅកាន់ទិសដៅ ដែលព្រះអង្គពុំបានយាងទៅនោះឯង ។

លោកសេដ្ឋីអនាថបិណ្ឌិក បានលើកនាងបុណ្ណាទាសី ឱ្យឋិតនៅក្នុងឋានៈជាធីតា នាងបុណ្ណាបានឱកាសក៏សូមបួសក្នុងព្រះពុទ្ធសាសនា កាលបួសហើយក៏ផ្ដើមចម្រើនវិបស្សនា ហើយព្រះអង្គទ្រង់ប្រទានឱវាទដោយគាថានេះថា :

**បុណ្ណេ បូរេសិ សទ្ធម្មំ ចន្ទោ បណ្ណរសោ យថា**
**បរិបុណ្ណាយ បញ្ញាយ ទុក្ខស្សន្តំ ករិស្សសិ ឱ**

ម្នាលនាងបុណ្ណា នាងចូរបំពេញនូវព្រះសទ្ធម្មឱ្យពេញ ដូចព្រះចន្ទក្នុងថ្ងៃ ១៥ កើត នាងនឹងធ្វើទីបំផុតនៃទុក្ខដោយបញ្ញាដែលបរិបូណ៌ (ឱ្យសម្រេច) បាន ។

ពេលចប់ព្រះគាថា ព្រះនាងបុណ្ណាថេរី បានសម្រេចនូវព្រះអរហត្ត ជាព្រះសាវិកាដ៏មានឈ្មោះល្បី[១] ។

ព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់ថា ស្ត្រីក៏អាចសម្រេចមគ្គផលបានដូចជាបុរសដែរ ដោយមិនមានអ្វីផ្សេងគ្នា

១_អដ្ឋកថា រថវិនីតសូត្រ ។



ឡើយ ។ ព្រះពុទ្ធសាសនាប្រដៅអប់រំឱ្យសម្លឹងមើលស្ត្រីដូចជាកូនស្រី បងស្រី ប្អូនស្រី ឬដូចជាម្ដាយតាមសមរម្យដល់វ័យ[១] ។ មនុស្សទាំងឡាយរហូតដល់ម៉ែឪ មិនត្រូវប្រព្រឹត្តលក់មនុស្ស លក់កូន លក់ចៅ ឱ្យទៅប្រព្រឹត្តផ្លូវភេទព្រោះហេតុតែរឿងអ្វីមួយឡើយ ។ ការជួញដូរមនុស្សព្រះពុទ្ធសាសនាចាត់ជាមិច្ឆាជីវៈ គឺការចិញ្ចឹមជីវិតខុស ។

ចំពោះជីវិតសោភិនី ព្រះពុទ្ធសាសនាពុំបានបន្ទុះបង្អាប់ មើលងាយមើលថោក ឬក៏លើកតម្កើងឡើយ ។ ព្រះពុទ្ធសាសនា មិនមានអគតិអ្វីចំពោះស្ត្រីភេទទេ គឺដោយច្រើន ព្រះពុទ្ធសាសនាតែងតែចង្អុលបង្ហាញប្រាប់នូវទោសរបស់កិលេសតណ្ហា ច្រើនជាងការតិះដៀលទៅលើបុគ្គល ។

បុរសដែលកាន់ព្រះពុទ្ធសាសនា ដើរលេងស្រីកម្សាន្តសប្បាយជាមួយស្រីពេស្យាបានដែរឬទេ ?

នៅក្នុងព្រះពុទ្ធសាសនានេះ បានចាត់ទុកគ្រហស្ថ

១_អដ្ឋកថា មហាបរិនិព្វានសូត្រ ត្រង់ចំណុចដែលព្រះអានន្ទទូលសួរព្រះសាស្តា អំពីការបដិបត្តិចំពោះស្ត្រី ។

ដែលដល់ព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃជាទីពឹងទីរលឹក ថាជា ឧបាសកឧបាសិកា។ ដើម្បីឱ្យបានទៅជាឧបាសកឧបាសិកាល្អ ត្រូវកាន់សីល ៥ ជានិច្ចកាល សមាទានឧបោសថ រក្សាកុសលកម្មបថ វៀរចាកការចិញ្ចឹមជីវិតខុស ឧស្សាហ៍ខ្មីឃ្មាតសិក្សាឱវាទនៃព្រះជិនស្រី ។ល។ ចំពោះសិក្ខាបទទី ៣ នៃសីល ៥ គឺវៀរចាកការប្រព្រឹត្តខុសក្នុងកាមទាំងឡាយ បានដល់ការមិនប្រព្រឹត្តផ្លូវភេទ (មេថុនធម្ម) ចំពោះស្ត្រីដែលជាទីហួងហែងនៃអ្នកដទៃ ។

បុរសដែលកាន់ព្រះពុទ្ធសាសនា កាលណាបើយល់ដល់សិក្ខាបទទី ៣ នៃសីល ៥ ដូច្នេះហើយ ក៏កើតការខ្មាសបាបព្រមដោយមាននូវកាមសំវរៈ ចេះសង្រួមក្នុងកាម មិនទៅទំនាក់ទំនងផ្លូវភេទជាមួយនឹងស្រីពេស្យាឡើយ ។ តាមពិតស្ត្រីទាំងនោះ ក៏ដូចជាកូនចៅ ឬបងស្រីប្អូនស្រី (គួរគិតថា មាតារបស់យើងក៏ជាស្រី ) ម្យ៉ាងទៀត ស្ត្រីទាំងនោះ ភាគច្រើនគឺនៅជាទីហួងហែងរបស់ម៉ែឪបងប្អូនរបស់គេទាំងស្រុង ។



កាលបើបានពិចារណាដោយសព្វគ្រប់ហើយ បុរសមិនគប្បីជាអ្នកលេងស្រីឡើយ ហើយក៏មិនត្រូវជ្រោមជ្រែងឱ្យកម្លាំងដល់កិលេសកាមដែលជាសត្រូវខាងក្នុងខ្លួននោះដែរ ។ ដើរលេងស្រីគឺជាការប្រព្រឹត្តនូវអបាយមុខដែលជាប្រធាននៃសេចក្តីវិនាស វាធ្វើឱ្យខូចសុខភាពទាំងសុខភាពកាយ ទាំងសុខភាពចិត្ត ខូចពេលវេលា ឬអាចខូចទាំងជីវិតទៀតផង ។ ត្រូវចាំទុកថា : កាមទាំងឡាយមានសេចក្តីសុខតិច មានទុក្ខច្រើន មានសេចក្តីចង្អៀតចង្អល់ច្រើន ទោសក្នុងកាមទាំងឡាយមានច្រើនក្រៃលែង ។

ព្រះពុទ្ធសាសនា ចាត់ទុកអ្នកដែលបោកបញ្ឆោតស្ត្រីយកទៅលក់ ថាយ៉ាងណាដែរ ?

បុគ្គលណា ដែលប្រើកលល្បិចបោកបញ្ឆោតស្ត្រីយកទៅលក់ក្នុងរឿងផ្សេងៗ ដោយច្រើនគឺលក់ឱ្យចូលទៅក្នុងបនស្រីពេស្យាចារ បុគ្គលនោះ ឈ្មោះថា ចិញ្ចឹមជីវិតខុស ។ ការចិញ្ចឹមជីវិតបែបនេះ មានតែអន្ធបុថុជ្ជន[១] តែ

១.ល្ងង់ខ្លៅ ងងឹតងងល់ដូចខ្វាក់ភ្នែក ។

ប៉ុណ្ណោះ ចំណែកកល្យាណបុថុជ្ជនមិនប្រព្រឹត្តសោះឡើយ ចាំបាច់និយាយថ្វីដល់ព្រះអរិយបុគ្គល ។

មុខជំនួញដែលបៀតបៀនដល់អ្នកដទៃ ក៏ជាការបៀតបៀនដល់ខ្លួនឯងផងដែរ ព្រះពុទ្ធសាសនា បានណែនាំឱ្យវៀរចាក ហើយត្រូវអប់រំចិត្តឱ្យជីវិតធ្វើដំណើរតាមផ្លូវបរិសុទ្ធ ទើបបានរួចផុតពីសេចក្ដីទុក្ខ ។



# ៦-ប្រយោជន៍នៃការសិក្សាព្រះពុទ្ធសាសនា សម្រាប់ស្ត្រី

មនុស្សជាសត្វដ៏ប្រសើរ ព្រោះមនុស្សបដិសន្ធិដោយកុសលវិបាក (ផលបុណ្យ) ដែលជាដើមទុន សម្រាប់ឱ្យមនុស្សអាចសិក្សាយល់ដឹងអំពីជីវិតរបស់ខ្លួនឯង និងអាចបំពេញសេចក្ដីល្អផ្សេងៗ ព្រមទាំងអាចអប់រំចិត្តទូន្មានខ្លួនឯងបាន ។ ការសិក្សាព្រះពុទ្ធសាសនា យកការចម្រើនបញ្ញាជាសំខាន់ ។ បញ្ញាដឹងពីសេចក្ដីពិតនៃជីវិត ដឹងពីសច្ចធម៌ជុំវិញជីវិត ដឹងហើយក៏លែងប្រកាន់ ចិត្តក៏មានសេចក្ដីស្ងប់នៅត្រង់ការមិនប្រកាន់នេះឯង ។

ការសិក្សាព្រះពុទ្ធសាសនា មិនចំពោះតែបុរសនោះឡើយ ស្ត្រីមានសិទ្ធិស្មើគ្នានឹងបុរសក្នុងការសិក្សាព្រះពុទ្ធសាសនា ។ រីឯប្រយោជន៍ដែលស្ត្រីបានសិក្សាចេះដឹងក្នុងព្រះពុទ្ធសាសនា មានដូចតទៅ :

**១-ប្រយោជន៍សម្រាប់ខ្លួនឯង** ក្នុងឋានៈជាមនុស្ស ដែលផ្សេងពីសត្វតិរច្ឆាន គឺនៅត្រង់សិក្សា ។ មនុស្សអាច សិក្សាបាន ហ្វឹកហាត់បាន រៀនដឹងបាន រហូតដល់ក្លាយជា មនុស្សប្រសើរទៅបាន ។ ការសិក្សារបស់មនុស្ស គឺសំដៅ ទៅរកការរីកចម្រើនគ្រប់បែប ដើម្បីសេចក្ដីសុខក្នុងជីវិត សិក្សារហូតទៅទល់គ្នានឹងសម្រេចបាននូវឥស្សរភាពពេញ ទី រួចពីទាសៈរបស់កិលេស ។ ស្ត្រីក៏ជាមនុស្ស បើស្ត្រី ទាំងឡាយបានសិក្សាយល់ដឹងពីព្រះពុទ្ធសាសនា ប្រាកដ ជាធ្វើឱ្យស្ត្រីទាំងឡាយនោះ ជឿមាំលើសមត្ថភាពរបស់ ខ្លួនឯងថា អាចអប់រំឱ្យចម្រើនដល់ទីបំផុតបាន ដោយមិន មានចំណុចខ្វះខាតអ្វីនោះឡើយ ព្រោះថា សតិក្ដី បញ្ញាក្ដី សេចក្ដីព្យាយាមក្ដី ពុំមែនស្រី ពុំមែនប្រុសទេ ។

**២-ប្រយោជន៍សម្រាប់គ្រួសារ** ស្ថាប័នគ្រួសារដែល មានការមាំមួនទៅបាន ចាំបាច់ត្រូវអាស្រ័យស្ត្រីយ៉ាងពិត ប្រាកដ ។ ស្ត្រីដែលជាម៉ែរបស់កូន ចាំបាច់ត្រូវចិញ្ចឹមនិង អប់រំកូនរបស់ខ្លួន ឱ្យកូនបានរស់ និងចម្រើនធំធាត់យ៉ាង



មានគុណភាព ។ ស្ត្រីដែលជាមាតា មានការរាប់អានកូន ដ៏យ៉ាងស្មោះ និងប្រណីតក្រៃលែងបំផុត ប្រព្រឹត្តទៅព្រម ដោយព្រហ្មវិហារ ។ ព្រះពុទ្ធសាសនា អប់រំមនុស្ស ក្នុង គោលធម៌បីយ៉ាង គឺ ១-កុំធ្វើបាបទាំងពួង , ២-ដល់ព្រម ដោយការបំពេញកុសល និង ៣-សម្អាតចិត្តរបស់ខ្លួនឱ្យ បានស្អាត (លាងជម្រះលោភៈ ទោសៈ មោហៈ កំណាញ់ ច្រណែន ... ) ដូច្នោះ កាលបើស្ត្រីបានសិក្សាព្រះពុទ្ធ-សាសនា ស្ត្រីរមែងប្រព្រឹត្តនូវគុណធម៌ បានយ៉ាងសមរម្យ តាមពេលវេលា និងស្ថានទី ។ មាតាដែលអប់រំកូនឱ្យដើរ ក្នុងផ្លូវល្អ គឺជាកល្យាណមិត្តរបស់កូន ។ មាតាមិនត្រឹមតែ ជាអ្នកឱ្យជីវិតកូនប៉ុណ្ណោះទេ មាតារមែងឱ្យគ្រប់យ៉ាង ដើម្បីកូនរបស់ខ្លួនបានជួបប្រសព្វនូវសេចក្ដីសុខ ។ មាតា ដែលប្រព្រឹត្តតាមព្រះពុទ្ធសាសនា រមែងបានជាអង្គគំរូ យ៉ាងល្អប្រពៃ ដែលធ្វើឱ្យកូនប្រុសស្រីនឹករលឹកឃើញដល់ សេចក្ដីល្អរបស់ម៉ែ ទឹកចិត្តម៉ែ ការឱ្យរបស់ម៉ែគ្រប់យ៉ាង ទាំងអាមិសទាន ទាំងអភយទាន និងទាំងធម្មទាន ។

កាលណាបើកូននឹករលឹកឃើញសេចក្ដីល្អរបស់ម៉ែ (រួមទាំងសេចក្ដីល្អរបស់បិតាផងដែរ ) កាលនោះឯង ឈ្មោះថា កូនដឹងគុណ ហើយកូននឹងឈរខាងសេចក្ដីល្អ ប្រកាន់យកអំពើល្អជាគុណតម្លៃនៃជីវិត ។

ក្នុងចំណុចទី ២ នេះ សូម្បីមានដល់បុរសជាបិតាផងដែរក៏ដោយ ប៉ុន្តែភាគច្រើនកូនប្រុសស្រីរមែងនៅជាមួយមាតាច្រើនជាង ដូច្នេះហើយ អ្វីៗដែលមាតាបានប្រព្រឹត្តទាំងកាយទាំងវាចាព្រមដោយចិត្ត រមែងចម្លងឧបនិស្ស័យឱ្យទៅកូន ។

**៣-ប្រយោជន៍ដល់សង្គមជាតិ និងសង្គមសាសនា** ក្នុងឋានៈស្ត្រីជាសមាជិក ក្នុងសង្គម ត្រូវតែមានសេចក្ដីសំខាន់ក្នុងការអភិវឌ្ឍសង្គម ។ ព្រះពុទ្ធសាសនា បានឱ្យមនុស្សគ្រប់គ្នាក្នុងសង្គម ចូលរួមក្នុងការអភិវឌ្ឍដល់សង្គមរបស់ខ្លួន ដូចជាក្នុងការរក្សាព្រះពុទ្ធសាសនា ឱ្យគង់វង្សបន្តអាយុព្រះពុទ្ធសាសនា ជាដើម ព្រះពុទ្ធទ្រង់ត្រាស់ថា[១]

១-អង្គុត្តរនិកាយបញ្ចកនិបាត កិម្ពិលសូត្រ ។



ភិក្ខុ ភិក្ខុនី ឧបាសក ឧបាសិកា ដែលគោរពក្នុងព្រះរតនត្រ័យ គោរពក្នុងការសិក្សារៀនសូត្រ រហូតដល់បដិបត្តិដោយសេចក្ដីគោរព ព្រមទាំងគោរពកោតក្រែងដល់គ្នានឹងគ្នា នេះជាហេតុជាបច្ច័យឱ្យព្រះពុទ្ធសាសនាមានការរីកចម្រើន ផ្សព្វផ្សាយទូលំទូលាយ ។ ប្រសិនបើទាំងប្រុសទាំងស្រី ទាំងគ្រហស្ថ ទាំងបព្វជិត ពេញចិត្តក្នុងការសិក្សាស្វែងរកការចេះដឹង ទាំងអប់រំចម្រើនសេចក្ដីស្ងប់ចិត្តផងព្រះពុទ្ធសាសនានិងសង្គមជាតិ រមែងមានសេចក្ដីចម្រើន។ ការសិក្សានូវព្រះពុទ្ធសាសនា រមែងធ្វើឱ្យស្ត្រីមានការជឿមាំក្នុងសមត្ថភាពរបស់ខ្លួនឯងខ្លាំងឡើង ហើយយល់ថា ព្រះពុទ្ធសាសនាសម្លឹងមើលស្ត្រីយ៉ាងស្មើភាពជាមួយនឹងបុរស ព្រោះព្រះពុទ្ធទ្រង់បានប្រកាសសមាសភាពនៃពុទ្ធបរិស័ទ មានទាំងស្ត្រី មានទាំងបុរសក្នុងការរក្សាទ្រទ្រង់ព្រះពុទ្ធសាសនា[១] ។ ស្ត្រីដែលបានរៀនដឹងនូវព្រះពុទ្ធសាសនាដូច្នេះហើយ រមែងជាកម្លាំងសំខាន់ក្នុង

១-មានក្នុងមហាបរិនិព្វានសូត្រ

ការសាងលោកឱ្យសុខស្ងប់បាន ដូចពាក្យថា «មាតា » ប្រែថា ស្ត្រីអ្នករាប់អាននូវកូន ក្នុងអត្ថន័យថា ទ្រទ្រង់សត្វលោកឱ្យបានសុខ ដោយការបរិច្ចាគយ៉ាងពិតប្រាកដ។

ក្នុងបិដកលេខ ៤៦ , ទំព័រ ៣៥ នកុលសូត្រ ព្រះសម្មាសម្ពុទ្ធ ទ្រង់ត្រាស់ជាមួយនឹងនកុលបិតាដូច្នេះថា ម្នាលគហបតី អ្នកពេញជាមានលាភហើយ ម្នាលគហបតី អត្តភាពជាមនុស្សអ្នកពេញជាបានដោយល្អហើយ ត្រង់ដែលអ្នកបាននកុលមាតាគហបតានី មកជាអ្នកអនុគ្រោះប្រាថ្នានូវប្រយោជន៍ ជាអ្នកទូន្មានប្រៀនប្រដៅ ។

សេចក្តីនៅក្នុងនកុលសូត្រ បានបញ្ជាក់ឱ្យឃើញសមត្ថភាពស្ត្រីក្នុងព្រះពុទ្ធសាសនា ដែលជាអ្នកអនុគ្រោះប្រាថ្នានូវប្រយោជន៍ឱ្យដល់ស្វាមី ដែលកំពុងតែឈឺធ្ងន់ ដោយពាក្យរំលឹកដាស់តឿនដូច្នេះថា បពិត្រគហបតី អ្នកកុំធ្វើមរណកាលទាំងសេចក្តីអាល័យឡើយ បពិត្រគហបតី កាលកិរិយារបស់បុគ្គល ដែលប្រកបដោយសេចក្តីអាល័យ រមែងនាំមកនូវទុក្ខផង កាលកិរិយារបស់បុគ្គលដែល



ប្រកបដោយសេចក្តីអាល័យ ព្រះដ៏មានព្រះភាគទ្រង់តិះ-ដៀលផង ។ បពិត្រគហបតី អ្នកប្រហែលជាមានសេចក្តីត្រិះរិះយ៉ាងនេះថា អំណើះអំពីអាត្មាអញទៅ នកុលមាតាគហបតានី នឹងមិនអាចដើម្បីចិញ្ចឹមនូវទារកទាំងឡាយ ទាំងគ្រប់គ្រងនូវឃរាវាសបានឡើយ ។ បពិត្រគហបតី ដំណើរនោះអ្នកមិនត្រូវយល់ឃើញយ៉ាងនោះឡើយ បពិត្រគហបតី ខ្ញុំជាស្ត្រីប្រសប់រវៃកប្បាស ឆ្មៀវឈ្លាសក្នុងការបួងផ្នួងសក់ ។ បពិត្រគហបតី អំណើះអំពីអ្នកទៅ ខ្ញុំអាចដើម្បីចិញ្ចឹមនូវទារកទាំងឡាយ ទាំងគ្រប់គ្រងនូវឃរាវាសបាន... ។ នកុលមាតា បានសម្តែងនូវសមត្ថភាពរបស់ខ្លួនច្រើនយ៉ាងទៀត ។

ក្នុងអដ្ឋកថាព្រះធម្មបទ សហស្សវគ្គ ក្នុងរឿងនាងកុណ្ឌលកេសី ទេវតាដែលស្ថិតនៅលើភ្នំទម្លាក់ចោរបានពោលពាក្យឱ្យសាធុការដល់នាងកុណ្ឌលកេសីថា :

**ន ហិ សព្វេសុ ឋានេសុ បុរិសោ ហោតិ បណ្ឌិតោ**
**ឥត្ថីបិ បណ្ឌិតា ហោតិ តត្ថ តត្ថ វិចក្ខណា ។**

មិនមែនតែបុរសទេ ដែលជាបណ្ឌិតក្នុងទីទាំងពួង សូម្បីស្ត្រីដែលមាននូវបញ្ញាឃើញប្រចក្ស ក៏ជាបណ្ឌិតបានក្នុងទីនោះៗ (ដូចគ្នាដែរ) ។

ក្នុងបិដកលេខ ២៩ , ទំព័រ ៨៣ អច្ឆរាសូត្រ ព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់ថា :

**ឧជុកោ នាម សោ មគ្គោ អភយា នាម សា ទិសា**
**រថោ អកុជ្ជនោ នាម ធម្មចក្កេហិ សំយុត្តោ ។**

ផ្លូវនោះ ឈ្មោះថាជាផ្លូវត្រង់ ទិសនោះឈ្មោះថាទិសមិនមានភ័យ រថឈ្មោះថារថមិនឮសូរ ប្រកបដោយកង់គឺសេចក្តីព្យាយាម ។

**ហិរី តស្ស អបាលម្ពោ សតស្ស បរិវារណំ**
**ធម្មាហំ សារថឹ ព្រូមិ សម្មាទិដ្ឋិបុរេជវំ ។**

ការខ្មាសបាបជាទ្រពងរទេះ(សម្រាប់ទប់អ្នកជិះកុំឱ្យធ្លាក់)សតិជាគ្រោះ(សម្រាប់រារាំងសរគឺកិលេស) តថាគតពោលថាធម៌គឺលោកុត្តរមគ្គជាសារថី មានសម្មាទិដ្ឋិស្ទុះទៅមុន ។



**យស្ស ឯតាទិសំ យានំ ឥត្ថិយា បុរិសស្ស វា**
**ស វេ ឯតេន យានេន និព្វានស្សេវ សន្តិកេ ។**

ជនណា ទោះស្រីឬប្រុស បានយានបែបនោះហើយ ជននោះឯង នឹងដល់នូវទីជិតនៃព្រះនិព្វាន ដោយយាននោះឯង ពុំខានឡើយ ។

ក្នុងបិដកលេខ ២៩ , ទំព័រ ២៣៤ ធីតុសូត្រ ព្រះសម្មាសម្ពុទ្ធ ទ្រង់ត្រាស់ប្រទាននូវឱវាទដល់ព្រះបាទ-បសេនទិកោសលថា :

**ឥត្ថីបិ ហិ ឯកច្ចិយា សេយ្យា បោស ជនាធិប**
**មេធាវិនី សីលវតី សស្សុទេវា បតិព្វតា ។**

បពិត្រព្រះអង្គជាធំជាងពពួកជន ដោយពិត សូម្បីស្ត្រីពួកខ្លះក៏មានកិរិយាមារយាទល្អត្រឹមត្រូវ ជាអ្នកមានសីល មានបញ្ញាឆ្លាតវៃ ប្រណិប័តន៍ឪពុកម្តាយក្មេកដូចទេវតា ព្រមទាំងប្រណិប័តន៍ស្វាមីដោយក្តីស្មោះ សូមព្រះអង្គទ្រង់ចិញ្ចឹមនូវធីតានោះចុះ ព្រោះនាងជាស្ត្រីដ៏ប្រសើរ ។

**តស្សា យោ ជាយតី បោសោ សូរោ ហោតិ និសម្បតិ**
**តានិសា សុភរិយា បុត្តោ វជ្ជិ អនុសាសតីតិ ។**

បុរសដែលកើតអំពីស្ត្រីនោះ រមែងជាមនុស្សក្លៀវ-ក្លា ជាធំគ្រប់ទិសទី គឺបុត្ររបស់ភរិយាល្អប្រាកដដូច្នោះ តែងប្រៀនប្រដៅនូវជនដែលនៅក្នុងដែនបាន ។

ក្នុងបិដកលេខ ៣៦ , ទំព័រ ៨២ មាតុគ្គាមសំយុត្ត ព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់សម្ដែងប្រាប់ដល់ភិក្ខុទាំងឡាយថា :

ម្នាលភិក្ខុទាំងឡាយ មាតុគ្រាមប្រកបដោយអង្គ៥ រមែងជាទីពេញចិត្តនៃបុរសយ៉ាងពិតប្រាកដ គឺមានតែការពេញចិត្តម្យ៉ាងប៉ុណ្ណោះ (**ឯកន្តមនាបោ ហោតិ បុរិ-សស្ស**)។ អង្គ៥គឺអ្វីខ្លះ ។ អង្គ៥គឺ

**១-រូបវា ច ហោតិ** មានរូបសមប្រកប

**២-ភោគវា ច ហោតិ** មានទ្រព្យសម្បត្តិ

**៣-សីលវា ច ហោតិ** មានសីលាចារ

**៤-ទក្ខោ ច ហោតិ អនលសោ** មានការវៃឆ្លាត



ប្រកបដោយសមត្ថភាព ហើយមិនខ្ជិលច្រអូស ។

**៥-បជញស្ស លភតិ** បានបុត្រ គឺមានកូនសម្រាប់ញ៉ាំងវង្សត្រកូលរបស់បុរសនោះឱ្យតម្កល់នៅ ។

②.ចំណុចទាំង៥នេះ

គប្បីប្រកបដោយកាលសម្បត្តិ ផង និងប្រកបដោយស្វាមីដែលមាននូវវិចារណញ្ញាណ ផង ។

ក្នុងសម័យពុទ្ធកាល មានស្ត្រីមិនតិចនាក់ឡើយ ដែលប្រកបដោយការចេះដឹងក្នុងព្រះពុទ្ធសាសនា ហើយបានជួយប្ដីព្រមទាំងញាតិខាងប្ដី ឱ្យរួចពីមិច្ឆាទិដ្ឋិ ដូចជា នាងវិសាខា កូនស្រីរបស់ធនញ្ជយសេដ្ឋី នាងឧត្តរា កូនស្រីរបស់បុណ្ណកសេដ្ឋី នាងចូឡសុភទ្ទា កូនស្រីរបស់អនាថ-បិណ្ឌិកសេដ្ឋី និងកុលធីតាក្រុងសាវត្ថី ដែលព្រះសម្មា-សម្ពុទ្ធទ្រង់ប្រារព្ធសុវណ្ណមិគជាតកជាដើម ។

ក្នុងបិដកលេខ ៥៩ , ទំព័រ ១៣ សុវណ្ណមិគជាតក ព្រះសម្មាសម្ពុទ្ធទ្រង់ប្រារព្ធកុលធីតា ដែលល្បីឈ្មោះព្រោះបានជួយស្វាមីរបស់ខ្លួន ។ អតីតជាតិ នាងជាម្រឹគញី បាន

ឮសម្រែកម្រឹគជាប្ដីជាប់អន្ទាក់ ហើយក៏បានស្ទុះទៅរកដល់ហើយបានពោលថា :

បពិត្រមហាម្រឹគ អ្នកចូរខំប្រឹង បពិត្រម្រឹគមានជើងដូចមាស អ្នកចូរខំប្រឹង ចូរកាត់នូវអន្ទាក់ដែលធ្វើដោយព្រ័ត្រ ខ្ញុំជាម្រឹគញីម្នាក់ឯង មិនអាចត្រេកអរក្នុងព្រៃបានទេ[១] ។

ម្រឹគជាប្ដីគឺព្រះបរមពោធិសត្វបានតបថា :

អង្គអញខំប្រឹងរើហើយមិនរួចទេ អង្គអញខំកកាយផែនដីដោយកម្លាំង[២] អន្ទាក់ដែលគេធ្វើដោយព្រ័ត្រជាប់មាំណាស់រឹតក្ងួតជើងអង្គអញ ។

ពេលនោះព្រានក៏បានមកដល់ ។ នាងម្រឹគក៏សម្ដែងនូវការគោរពចំពោះនាយព្រាន រួចហើយបានពោលនូវគុណសម្បត្តិរបស់មហាសត្វថា : បពិត្រព្រានស្វាមីរបស់នាងខ្ញុំម្ចាស់ មានពណ៌ដូចមាស សម្បូណ៌ដោយសីល មានមារយាទល្អ ជារាជារបស់ម្រឹគយ៉ាងច្រើនក្នុង

១. បើអត់ពីអ្នកទៅ ខ្ញុំនឹងមិនបរិភោគទឹកស្មៅ អដ្ឋកថា ។

២. កកាយដីឱ្យសណ្ដកអន្ទាក់ ។



ព្រៃ ។ ហើយបានពោលបន្តទៀតថា :

បពិត្រព្រាន អ្នកចូរក្រាលនូវស្លឹកឈើ អ្នកចូរហូតដាវអំពីស្រោម អ្នកសម្លាប់ខ្ញុំមុន ហើយសឹមសម្លាប់មហាម្រឹគជាប្ដីខ្ញុំតាមក្រោយ ។

នាយព្រានបានស្ដាប់ដូច្នោះហើយ ទើបគិតថា នាងម្រឹគនេះជាសត្វតិរច្ឆានហ៊ានបរិច្ចាគជីវិត ដែលសូម្បីតែមនុស្សក៏ធ្វើបានដោយក្រ ថែមទាំងពោលភាសាមនុស្សដោយសំឡេងដ៏ពីរោះទៀត នាយព្រានគិតដូច្នេះរួចហើយក៏បានពោលថា :

យើងមិនដែលឮ ឬឃើញមេម្រឹគចេះនិយាយភាសាមនុស្សទេ ម្នាលមេម្រឹគដ៏ចម្រើន នាងចូរនៅជាសុខចុះ ទាំងមហាម្រឹគនោះ ក៏សូមឱ្យនៅជាសុខផងដែរ ។

កាលដែលនាយព្រានលែងមហាសត្វជាប្ដីហើយ នាងម្រឹគមានអំណរដ៏ពន់ពេក ហើយបានពោលពាក្យឱ្យពរដូច្នេះថា :

បពិត្រអ្នកព្រាន ខ្ញុំត្រេកអរ ព្រោះឃើញនូវមហា-

ម្រឹគរួចពីអន្ទាក់ ក្នុងថ្ងៃនេះ យ៉ាងណា សូមឱ្យអ្នកត្រេកអរជាមួយនឹងពួកញាតិទាំងអស់ យ៉ាងនោះដែរ ។

ព្រះមហាសត្វគិតថា នាយព្រាននេះជាទីពឹងអាស្រ័យរបស់យើង សូម្បីយើងក៏គួរជាទីពឹងអាស្រ័យរបស់នាយព្រាននេះដែរ ទើបបានឱ្យកែវមណីដល់នាយព្រាន ដែលខ្លួនបានជួបកែវមណីនោះនៅកន្លែងមួយ ។ ព្រះមហាសត្វ បានប្រទានឱវាទដល់ព្រាននោះថា : ម្នាលសម្លាញ់ ចាប់តាំងតែពីពេលនេះទៅ អ្នកកុំធ្វើបាបមានការសម្លាប់សត្វជាដើមទៀតឡើយ អ្នកចូរចិញ្ចឹមបុត្រភរិយារបស់អ្នក ព្រមដោយការធ្វើទាន ដោយដុំកែវមណីនេះចុះ។

នាយព្រានបានមកជាឆន្នអាមាត្យ នាងម្រឹគបានមកជាកុលធីតា ដែលក្រោយមកនាងបានចូលកាន់ផ្នួសជាមួយនឹងស្វាមីរបស់នាង ហើយបានសម្រេចនូវព្រះអរហត្តផល ឯស្តេចម្រឹគសម្បុរពណ៌មាស បានមកជាព្រះតថាគត ។

ក្នុងព្រះសាសនានៃព្រះសម្មាសម្ពុទ្ធកស្សបៈ មាន



មហាក្សត្រមួយព្រះអង្គដ៏ល្បីល្បាញ ទ្រង់ព្រះនាមព្រះបាទកិកិ ។ កាលដើមឡើយទ្រង់រាប់អានពួកព្រាហ្មណ៍ ប៉ុន្តែដោយសារមានបុត្រីដ៏ឆ្លាតវៃក្នុងព្រះពុទ្ធសាសនា ក្រោយមកព្រះអង្គក៏ទ្រង់បានសម្រេចនូវសោតាបត្តិផល[១] ។ ព្រះរាជធីតាព្រះនាម **ឧរច្ឆនា** មានរូបស្រស់សោភា ឈប់ជ្រះថ្លានឹងពួកព្រាហ្មណ៍ទាំងឡាយ ព្រោះហេតុតែពួកព្រាហ្មណ៍ទាំងនោះបែកធ្លាយឥន្ទ្រិយ សម្លឹងមើលនាង ។ ព្រះនាងបានជ្រះថ្លានឹងព្រះអគ្គសាវ័ក បានប្រគេនចង្ហាន់ហើយស្តាប់ព្រះធម៌ សម្រេចសោតាបត្តិផល ។ ព្រះនាង **ឧរច្ឆនា** មានឧបការគុណដ៏ក្រៃលែងដល់មហាជនក្នុងដែនកាសី ព្រោះហេតុបានជួយឱ្យព្រះរាជបិតាតាំងនៅក្នុងព្រះពុទ្ធសាសនា ។

ក្នុងពុទ្ធកាលនេះឯង ព្រះនាងមល្លិកាបានជួយព្រះស្វាមីគឺព្រះបាទបសេនទិកោសលក៏ក្រៃលែង ។ ព្រះរាជាអង្គនេះ ដើមឡើយក៏មិនទាន់ជ្រះថ្លាស៊ប់សួនក្នុងព្រះពុទ្ធ-

១-បិដកលេខ ២៤ , ទំព័រ ២៥៩ ឃដិការសូត្រ និង អដ្ឋកថា ។

សាសនាដែរ បានភ្ញាក់ផ្អើលក្នុងរឿងផ្សេងៗ ហើយចាត់ចែងឱ្យគេរៀបចំបូជាយញ្ញ ប្រុងប្រៀបសម្លាប់មនុស្សសត្វយ៉ាងច្រើន ប៉ុន្តែបានព្រះនាងមល្លិកា ជួយនាំព្រះអង្គទៅគាល់ព្រះសម្មាសម្ពុទ្ធ ទើបទ្រង់បានយល់ដឹងពីហេតុ-ផល បញ្ជាឱ្យគេដោះលែងមនុស្សសត្វទាំងនោះ។ព្រះនាងមល្លិកាឆ្លាតវៃល្បីល្បាញក្នុងព្រះពុទ្ធសាសនា បានជួយព្រះរាជាក្នុងរឿងច្រើនទៀត ព្រះនាងមានឧបការគុណដល់ប្រជាជនក្នុងក្រុងសាវត្ថី ។



# ៧-បញ្ហាផ្សេងៗ

១- ហេតុដូចម្តេចបានជាក្នុងព្រះវិន័យ មានគរុធម៌ឱ្យភិក្ខុនីថ្វាយបង្គំភិក្ខុ?

- ព្រះសម្មាសម្ពុទ្ធទ្រង់អនុញ្ញាតឱ្យស្ត្រីមកបួសក្នុងព្រះពុទ្ធសាសនា គឺជាប្រវត្តិសាស្ត្រដ៏សំខាន់របស់ស្ត្រីក្នុងសម័យនោះ ។ ព្រះអង្គជាមហាវីរបុរសទី១ ដែលជួយស្ត្រីក្នុងលោក អាចនិយាយបានថាព្រះអង្គតស៊ូដើម្បីសិទ្ធិស្ត្រីក៏បាន ។ យើងបានជ្រាបតាមប្រវត្តិសាស្ត្រហើយមនុស្សក្នុងសម័យមុននោះ គេចាត់ទុកស្ត្រីភេទថាមិនបានការយ៉ាង-ណាខ្លះ ។ តាមកុលសម្ព័ន្ធដែលប្រមូលកម្លាំងគ្នា គេនិយមកម្លាំងបាយជាសំខាន់ ហើយគេចាត់ទុកស្ត្រីជាអ្នកបម្រើក្បែរជើងរបស់គេដែលជាបុរស ដូច្នេះទើបមានពាក្យថា «បាទបរិចារិកា » ។ បាទបរិចារិកា គឺភរិយាហ្នឹងឯងហើយបុរសអាចមានបាទបរិចារិកាដល់រាប់សិបនាក់ ដល់

រាប់រយ រាប់ពាន់នាក់ទៀតផង។ ទៅតាមលទ្ធិសាសនាដទៃៗក៏គេមិនលើកតម្កើងស្ត្រីឡើយ គេចាត់ទុកស្ត្រីថាជាភេទមិនបរិសុទ្ធ[១] ។

- តាមព្រះវិន័យព្រះពុទ្ធសាសនា តម្រូវឱ្យភិក្ខុនីថ្វាយបង្គំភិក្ខុ មិនមែនជារឿងមើលងាយចំពោះភេទស្ត្រីឡើយ ។ តាមពិតព្រះពុទ្ធទ្រង់រៀបចំចាត់ចែងឱ្យភិក្ខុមើលថែភិក្ខុនីណាស់ ដូចបងប្រុសមើលថែប្អូនស្រីអ៊ីចឹងឯង ។ ច្បាប់ភិក្ខុនី មិនត្រូវនៅចាំវស្សាក្នុងអាវាសដែលមិនមានភិក្ខុឡើយ ។ ម្យ៉ាងទៀត ភិក្ខុនីត្រូវទទួលយកឱវាទអំពីភិក្ខុរាល់កន្លះខែ រីឯភិក្ខុជាអ្នកប្រទានឱវាទត្រូវប្រកបដោយអង្គ៨ គឺ ១-ភិក្ខុជាអ្នកមានសីល សង្រួមតាមបាតិមោក្ខ-សំវរៈ បរិបូណ៌ដោយអាចារ(មារយាទ)និងទីគោចរ ជាអ្នកឃើញភ័យក្នុងទោសទាំងឡាយ(សូម្បីទោសនោះ)មានប្រមាណតិចតួច សមាទានសិក្សាក្នុងសិក្ខាបទទាំងឡាយ ២-ភិក្ខុជាពហុស្សូតទ្រទ្រង់ពុទ្ធវចនៈ សន្សំនូវពុទ្ធវចនធម៌ទាំងឡាយណា ពីរោះខាងដើម ពីរោះកណ្តាល ពីរោះ

១. តាមរយៈការអានសៀវភៅផ្សេងៗ ។



ខាងចុង តែងប្រកាសនូវព្រហ្មចរិយធម៌ព្រមទាំងអត្ថទាំងព្យញ្ជនៈ ឱ្យបរិសុទ្ធបរិបូណ៌ទាំងអស់ ធម៌ទាំងឡាយមានសភាពយ៉ាងនេះ ភិក្ខុនោះចាំច្រើនហើយ ទ្រទ្រង់ហើយ សន្សំហើយ ដោយវាចាដ៏ស្ទាត់រត់មាត់ ចូលចិត្តច្បាស់-លាស់ យល់ត្រូវល្អដោយទិដ្ឋិ(គឺបញ្ញា) ៣-ចំណែកព្រះបាតិ-មោក្ខទាំងពីរ ភិក្ខុនោះក៏ចេះចាំដោយពិស្តារ ចែកចេញបានដោយប្រពៃ ចាំស្ទាត់រត់មាត់ កាត់សេចក្តីបានដោយល្អដោយសុត្ត(គឺខន្ធកៈនិងបរិវារៈ)ដោយអនុព្យញ្ជនៈ ៤-ភិក្ខុនោះ មានវាចាពោលត្រឹមត្រូវដោយសិថិលធនិតជាដើមមានសំឡេងពីរោះ ៥-ភិក្ខុនោះជាទីស្រឡាញ់ពេញចិត្តនៃភិក្ខុនីទាំងឡាយដោយច្រើន ៦-ភិក្ខុនោះជាអ្នកអាចដើម្បីនឹងឱ្យឱវាទដល់ភិក្ខុនីបាន ៧-ភិក្ខុនោះមិនធ្លាប់ប្រព្រឹត្តកន្លងនូវគរុធម៌ជាមួយនឹងភិក្ខុនី ដែលស្លៀកដណ្តប់សំពត់ជ្រលក់ដោយទឹកចត់ បួសចំពោះព្រះដ៏មានព្រះភាគនេះ ៨-ភិក្ខុនោះមានវស្សា២០ឬមានវស្សាជាង២០ ។ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឱ្យសង្ឃសន្មតនូវភិក្ខុដែល

ប្រកបដោយអង្គទាំងឡាយ ៨ នេះ ឱ្យជាអ្នកផ្តល់ឱវាទចំពោះភិក្ខុនី[១] ។

តាមការពិនិត្យដោយល្អិតល្អន់ យើងឃើញថាភិក្ខុមានកិច្ចត្រូវមើលថែភិក្ខុនីក្នុងនាមជាបងប្រុសនិងក្នុងនាមជាគ្រូអាចារ្យ ។

-ការគោរព សំពះ ថ្វាយបង្គំ គឺជាគុណធម៌ដ៏សំខាន់ មិនមែនបានសេចក្តីថាអន់ថយនោះឡើយ ជាកិច្ចបដិបត្តិរក្សាព្រះធម៌ព្រះវិន័យដ៏សមគួរ តាមដែលព្រះពុទ្ធអង្គទ្រង់សម្តែងនិងបញ្ញត្តហើយ ។

**គោបិកាសក្យធីតា** ជាឧបាសិកាទំនុកបម្រុងភិក្ខុសង្ឃបូជាថ្វាយបង្គំព្រមទាំងទទួលយកឱវាទអំពីភិក្ខុនោះៗ លុះដល់អស់ជីវិត គោបិកាឧបាសិកា បានជាទេវបុត្រនៅឋានតាវត្តិង្សឈ្មោះគោបកៈ ជាបុត្រនៃសក្កទេវរាជ ។ ឯចំណែកភិក្ខុបីអង្គជាអ្នកផ្តល់ឱវាទ លុះអស់ជីវិតបានកើតក្នុងកំណើតគន្ធព្វ គឺទេវតារបាំ(ទេវតាថ្នាក់ចាតុម្មហារាជិកាទិសខាងកើត) ។ លុះដល់ទេវតាគន្ធព្វទៅបម្រើព្រះឥន្ទ

១. បិដកលេខ ៤ , ទំព័រ ៣០-៣១



ទើបគោបកទេវបុត្ររំលឹកដាស់តឿនដោយពាក្យថា «អ្នកទាំងឡាយយកមុខទៅទុកក្នុងទីណា...[១]» ។

-ការរៀបចំស្ថាប័នសាសនា ព្រះសម្មាសម្ពុទ្ធទ្រង់រៀបចំដោយសព្វញ្ញុតញ្ញាណ ដើម្បីឱ្យសាសនាតាំងនៅបានយូរ ។ យើងក៏គួរជ្រាបហើយថា ការដែលឱ្យស្រីមកនៅជាមួយប្រុស វាមានបញ្ហាយ៉ាងណា។ ដូច្នេះភិក្ខុនីដែលប្រព្រឹត្តរក្សានូវគរុធម៌ទាំង៨ប្រការ[២] ឈ្មោះថាបានរក្សានូវព្រះពុទ្ធសាសនា ឱ្យឋិតនៅបានយូរ។ សូមជ្រាបថានេះជាព្រះវិន័យ តែបើតាមផ្លូវធម៌វិញ ត្រូវគោរពកោតក្រែងគ្នាទៅវិញទៅមក ទើបព្រះសទ្ធម្មឋិតនៅបានយូរអង្វែង[៣] ។

- ប្រយោជន៍សំខាន់បំផុតនៅក្នុងធម្មវិន័យនេះ គឺមិនមែននៅលើលាភយស ឋានៈឬការគោរពលើកតម្កើងនោះទេ តាមពិត ទាំងភិក្ខុ ទាំងភិក្ខុនី ប្រព្រឹត្តព្រហ្មចរិយធម៌ក្នុងធម្មវិន័យនេះ ដើម្បីការរួចផុតចាកទុក្ខ ព្រោះកម្ចាត់បង់នូវតណ្ហាបានសម្រេច ។ បុគ្គលដែលអស់តណ្ហា បាន

១. បិដកលេខ១៧ ទំព័រ២០៧ សក្កបញ្ហសូត្រ ។ ២.បិដកលេខ ១១ ភិក្ខុនីខន្ធកៈ ។ ៣. បិដកលេខ ៤៥ , ទំព័រ២៣៨ ។

ដល់ត្រើយនៃភពបី លែងទាមទារអ្វីទៀតទាំងអស់ នេះទើបជាការសម្រេចសិទ្ធិអំណាចរបស់ខ្លួនដល់ទីបំផុត មានឥស្សរៈមានសេរីភាពគ្រប់យ៉ាង ឈប់ជាទាសៈនៃតណ្ហាក្នុងវដ្តសង្សារតទៅទៀត ។

២- ហេតុដូចម្ដេចបានជាស្ត្រីមិនអាចត្រាស់ដឹងជាព្រះសម្មាសម្ពុទ្ធ?

- ទាក់ទងទៅនឹងពុទ្ធការកធម៌ និងមហាបរិច្ចាគដែលព្រះបរមពោធិសត្វត្រូវបំពេញ អស់កាលដ៏យូរអង្វែងនោះ បើតាំងនៅក្នុងភេទជាស្រីគឺមិនអាចនឹងបំពេញឱ្យដល់កម្រិតបានឡើយ ដូច្នេះនិយតបរមពោធិសត្វ ត្រូវឋិតនៅក្នុងភេទជាបុរស។មុននឹងចូលមកជានិយតបរមពោធិសត្វ ព្រះអង្គក៏ធ្លាប់ជាស្ត្រីភេទដែរ ។ រឿងស្រីរឿងប្រុសមនុស្សយើងម្នាក់ៗ សុទ្ធតែធ្លាប់ចាប់កំណើតដូចគ្នា ស្ត្រីក៏ប្រាថ្នាជាព្រះសម្មាសម្ពុទ្ធបានដែរ ។

- ព្រះសម្មាសម្ពុទ្ធចាំបាច់ត្រូវតែឋិតនៅក្នុងភេទជាបុរស ព្រោះមនុស្សក្នុងសម័យព្រះពុទ្ធត្រាស់ដឹងនោះៗ គេ



ប្រកាន់រឿងស្រីប្រុសនេះណាស់ ដូច្នេះបើព្រះពុទ្ធជាស្រីមនុស្សភាគច្រើននោះគេមិនគោរពព្រះពុទ្ធឡើយ ហើយក៏មិនបានស្តាប់ធម៌ ។ តាមពិតព្រះសម្មាសម្ពុទ្ធផ្ទាល់ព្រះអង្គទ្រង់ពុំបានប្រកាន់ខ្លួនព្រះអង្គ ដោយមានះណាមួយឡើយ តែ ព្រះពុទ្ធត្រូវតែបដិសន្ធិនៅក្នុងត្រកូលខ្ពង់ខ្ពស់ជាចាំបាច់ ទោះក្សត្រឬព្រាហ្មណ៍ មូលហេតុ ដើម្បីឱ្យមនុស្សដែលប្រកាន់ត្រកូល ប្រកាន់វណ្ណៈនោះៗ គេព្រមគោរពព្រះអង្គ ហើយស្តាប់ព្រះធម៌ លុះដល់គេបានស្តាប់ហើយឃើញសច្ចធម៌ ទើបគេដឹងច្បាស់ដោយខ្លួនឯងថា « ខ្លឹមសារនៃជីវិតមិនមែននៅលើវណ្ណៈឬភេទជាដើមឡើយ » ។

- យើងអាចគិតថា អតីតជាតិរបស់ព្រះអង្គក៏ជាស្រីគ្រាន់តែដូរភេទមកជាប្រុស ហើយត្រាស់ដឹងជាព្រះសម្មាសម្ពុទ្ធ ដើម្បីជួយសត្វលោកតែប៉ុណ្ណោះ។ តាមពិត«ពុទ្ធ» ដោយសភាវធម៌គឺមិនមែនស្រីមិនមែនប្រុសឡើយ គឺជាបញ្ញាចាក់ធ្លុះនូវអរិយសច្ចៈទាំង ៤ ។ ព្រះអង្គចម្លងនូវ «ពុទ្ធ» មកឱ្យសត្វលោកតាមរយៈនៃការសម្តែងធម៌របស់

ព្រះអង្គ ។ « ពុទ្ធ » ជាទីប្រជុំនៃពោធិបក្ខិយធម៌ ៣៧ ប្រការ អាចមកឋិតនៅក្នុងបុរសក៏បាន ស្ត្រីក៏បាន ហើយកម្ចាត់បង់នូវអវិជ្ជាពីបុរសនោះ ស្ត្រីនោះឱ្យអស់ទៅបាន ។ សព្វថ្ងៃពុទ្ធបរិស័ទមិនបានឃើញព្រះរូបកាយនៃព្រះអង្គ តែអាចឃើញ «ពុទ្ធ» ដោយសភាវៈបាន តាមរយៈនៃបញ្ញាចាក់ធ្លុះនូវសច្ចធម៌ ។ ក្រៅអំពីព្រះសម្មាសម្ពុទ្ធ មិនមាននរណាក្នុងលោកនេះ និងក្នុងលោកដទៃ អាចដឹងបញ្ញារបស់ព្រះសម្មាសម្ពុទ្ធដោយសព្វគ្រប់ឡើយ ប៉ុន្តែ ការឃើញនូវសច្ចធម៌នៃបុគ្គលណា ដែលជាសាវ័កនៃព្រះពុទ្ធនោះ បុគ្គលនោះឯង ល្មមនឹងដឹងបានថា ព្រះពុទ្ធពិត ព្រះធម៌ពិត ព្រះសង្ឃពិត ។

- មារាធិរាជ ក៏មិនមានភេទជាស្ត្រីដែរ គឺជាទេវបុត្តមារ។ចំណុចនេះតើយើងគិតយ៉ាងណាដែរ ? តាមពិត អ្វីដែលសំខាន់បំផុតក្នុងជីវិតមនុស្សយើង ក៏ដូចជាជីវិតសត្វលោកដទៃ គឺបញ្ញា ។ បញ្ញាទើបអាចច្បាំងឈ្នះកិលេសក្នុងខ្លួនបាន ហើយផុតទុក្ខផុតភ័យ ។ សូមឱ្យ



ប្រាកដច្បាស់គ្រប់គ្នាថា «បញ្ញាមិនមែនប្រុស មិនមែនស្រីឡើយ» ។

៣- ហេតុដូចម្ដេចបានជាក្នុងគម្ពីរព្រះពុទ្ធសាសនា មានកន្លែងខ្លះតិះដៀលស្ត្រី ដូចពាក្យថា «ស្ត្រីជាមន្ទិលដល់ព្រហ្មចរិយធម៌[១]» និងឃើញមាននៅក្នុងព្រះជាតកផ្សេង១ ដូចក្នុងកុណាលជាតកជាដើម ?

- តាមពិត មិនមែនតែស្ត្រីទេ ដែលជាមន្ទិលដល់ព្រហ្មចរិយធម៌ រូប សំឡេង ក្លិន រស និងផោដ្ឋព្វៈរបស់បុរសក៏គ្របសង្កត់ចិត្តរបស់ស្ត្រី ហើយឋិតនៅបានដូចគ្នាដែរ[២] ។

- ការសម្ដែងព្រះធម៌របស់ព្រះពុទ្ធអង្គ ដល់បុគ្គលដែលនឹកអាល័យទៅរកភេទដែលផ្ទុយគ្នា ព្រះអង្គត្រូវរំលឹកឱ្យមានស្មារតីក្នុងការរក្សាព្រហ្មចរិយធម៌ ទៅតាមឧបនិស្ស័យនៃបុគ្គលម្នាក់១ ។

- អ្វីដែលជាមន្ទិលសៅហ្មង តាមពិតគឺជាកិលេស

---

១.ឧប្បថសូត្រ បិដកលេខ ២៩ , ទំព័រ ៩៨ ។

២.បិដកលេខ ៤០ , ទំព័រ ៣ ។

ក្នុងចិត្តនៃបុគ្គលម្នាក់ៗ រៀងៗ ខ្លួន គ្រាន់តែមានរូប សំឡេង ក្លិន រស និងផោដ្ឋព្វៈ ក្នុងបុគ្គលដែលមានភេទផ្ទុយគ្នាជាអារម្មណ៍ប៉ុណ្ណោះ ។

- បើមិនទាក់ទិនក្នុងរឿងអ្នកបួសទេ ព្រះពុទ្ធទ្រង់ត្រាស់ថា «**ភរិយា បរមា សខា** ភរិយាជាមិត្តសម្លាញ់ដ៏ក្រៃលែង[១]» ។ ម្យ៉ាងទៀត ក្នុងអបរិហានិយធម៌ ៧ យ៉ាង[២] ជាធម៌បដិបត្តិនាំឱ្យមានសេចក្តីចម្រើន មិនមានសេចក្តីសាបសូន្យឡើយ ។ ក្នុងចំណុចទី ៥ គឺការថែរក្សាស្ត្រីក្នុងត្រកូល ( ទាំងម្តាយទាំងកូនស្រី ) ឱ្យរស់នៅដោយល្អ មិនគំរាមកំហែង មិនចាប់បង្ខំឱ្យនៅរួម (ក្នុងអំពើអនាចារ ) សេចក្តីចម្រើនតែងមានប្រាកដក្នុងដែនសេចក្តីសាបសូន្យមិនមានឡើយ ។

- ព្រះនាងមទ្រីបានពោលទៅរកព្រះបាទសញ្ជយ-មហារាជ ជាព្រះបិតាក្មេកដូច្នេះថា[៣] :

១.វត្តសូត្រ បិដកលេខ ២៩ , ទំព័រ ៩៦ ។

២.បិដកលេខ ៤៧ , ទំព័រ ២៨ ។

៣.បិដកលេខ ៦៣ , ទំព័រ ១២៥ ។



**យា ទលិទ្ទី ទលិទ្ទស្ស អឌ្ឍា អឌ្ឍស្ស កិត្តិមា**
**តំ វេ ទេវា បសំសន្តិ ទុក្ករំ ហិ ករោតិ សា ។**

ស្ត្រីណាដែលមានកិត្តិយស កេរ្តិ៍ឈ្មោះ កាលស្វាមីទ័លក្រ ក៏ជាស្ត្រីរួមទ័លក្រជាមួយដែរ កាលស្វាមីស្តុកស្តម្ភក៏ជាស្ត្រីរួមស្តុកស្តម្ភជាមួយស្វាមីផងដែរ ពួកទេវតារមែងសរសើរស្ត្រីនោះឯង ព្រោះថា ស្ត្រីនោះធ្វើអំពើដែលគេធ្វើបានដោយក្រ ។

- ក្នុងព្រះសាសនានេះ ស្ត្រីដែលជាបណ្ឌិត ជាសប្បុរសនិងជាព្រះអរិយបុគ្គលមានច្រើនណាស់ ។ ដូច្នេះការសិក្សាព្រះធម៌ត្រូវសិក្សាទិសដៅនៃព្រះធម៌ បំណងនៃឱវាទ បុគ្គលអ្នកស្តាប់ អធ្យាស្រ័យអ្នកសម្តែង ។ល។ ដើម្បីកុំឱ្យច្រឡំក្នុងការបដិបត្តិ ។

៤.កន្លែងខ្លះគេថា ភេទស្រី ជាភេទមិនបរិសុទ្ធ គេមិនឱ្យចូលទៅកៀកជិតគល់ព្រះពោធិព្រឹក្ស ឬឡើងទៅថ្នាក់លើដើម្បីថ្វាយបង្គំព្រះពុទ្ធប្បដិមាឡើយ តើរឿងនេះយ៉ាងដូចម្តេចដែរ ?

- ព្រះសម្មាសម្ពុទ្ធ ពុំបានសម្តែងថា បុរសទើបបរិសុទ្ធ ឯស្ត្រីមិនបរិសុទ្ធឡើយនោះទេ ប៉ុន្តែព្រះអង្គទ្រង់ត្រាស់សម្តែងថា :

«បុគ្គលធ្វើបាបដោយខ្លួនឯង រមែងសៅហ្មងដោយខ្លួនឯង មិនធ្វើបាបដោយខ្លួនឯងទេ រមែងបរិសុទ្ធដោយខ្លួនឯង បរិសុទ្ធឬមិនបរិសុទ្ធជារបស់ចំពោះខ្លួន អ្នកដទៃមិនអាចញុំាងអ្នកដទៃឱ្យបរិសុទ្ធបានឡើយ[១] » ។

- ចំពោះភេទស្រី ដែលជាហីនភេទ មិនត្រូវប្រែថាជាភេទថោកទាប ឬភេទមិនបរិសុទ្ធនោះទេ ត្រូវប្រែថាភេទទន់ខ្សោយ ឯការទន់ខ្សោយនេះចំពោះតែរូបកាយប៉ុណ្ណោះ ទៅតាមច្បាប់ធម្មជាតិ ។ម្យ៉ាងទៀតគួរឃើញដល់ទុក្ខរបស់ស្ត្រី ៥ យ៉ាង[២] ដែលមិនមានចំពោះបុរស ។ ៥ យ៉ាងគឺ

(១)-ប្រាសចាកអំពីញាតិ ទៅកាន់ត្រកូលខាងប្តីទាំងនៅក្មេង ( ស្វាមីគួរផ្តល់នូវភាពកក់ក្តៅឱ្យដល់ភរិយារបស់ខ្លួន ) ។

១-ធម្មបទ អត្តវគ្គ ។ ២-បិដកលេខ ៣៦ , ទំព័រ ៨៤ ។



(២)-មានរដូវ (ពេលខ្លះបង្កបញ្ហាឱ្យកើតមានការប្រែប្រួលផ្លូវចិត្ត បុរសគួរយល់ ) ។

(៣)-មានគភ៌ (នាងប្រាថ្នាការយកចិត្តទុកដាក់អំពីស្វាមី ពិសេសជាងធម្មតា ។ ស្វាមីត្រូវទំនុកបម្រុងកាយចិត្តនាងដោយគុណធម៌ ឱ្យនាងបានជាមាតាល្អរបស់កូន)។

(៤)-សម្រាលកូន ( ជាពេលដែលនាងឈឺលំបាកខ្លាំងផ្លូវកាយ ទាក់ទងដល់អាយុជីវិតទៀតផង ។ ស្វាមីត្រូវយកចិត្តទុកដាក់ ហាក់ដូចជាទុក្ខលំបាកផ្ទាល់ខ្លួន ) ។

(៥)-បម្រើស្វាមី(ស្វាមីមិនត្រូវគិតតែពីខ្លួនឯងនោះឡើយ ត្រូវមានមេត្តា ករុណា មានការអើពើដោយទឹកចិត្តតបស្នងវិញ ) ។

ពិតមែនតែស្ត្រីមានកម្លាំងកាយទន់ខ្សោយ ប៉ុន្តែកម្លាំងចិត្តមិនខ្សោយឡើយ ព្រោះទៅតាមសេចក្តីពិតហើយនោះ ស្ត្រីមានសេចក្តីអត់ធន់ មានការលះបង់ដ៏យ៉ាងខ្ពង់ខ្ពស់ ក្នុងការចិញ្ចឹមបីបាច់ថែរក្សាកូន និងស្មោះស្ម័គ្រចំពោះស្វាមី ។ នោះពោលចំពោះស្ត្រីក្នុងព្រះពុទ្ធ-

សាសនា ដែលបានអប់រំបន្ទុំឧបនិស្ស័យក្នុងគុណធម៌ទាំង-ឡាយ ។

-**ហីនា ធម្មា** ពួកធម៌ថោកទាប បានដល់អកុសល-ចិត្តុប្បាទ ១២ ដួង ឯពួកធម៌សៅហ្មង បានដល់កិលេសទាំងឡាយ ។ សូមកុំច្រឡំអកុសលធម៌ទាំងអស់នេះ ថាជាស្ត្រីភេទឱ្យសោះ ។

៥-ក្នុងបាលីតែងតែយកភេទប្រុសមកសម្តែង ប៉ុន្តែខ្លឹមសាររួមទាំងស្រីផងដែរ ដូចជា **បុរិសទម្មសារថិ** ឬ **សទ្ធីធ វិត្តំ បុរិសស្ស សេដ្ឋំ** ជាដើម តើគួរយល់ដឹងយ៉ាងណា ?

- ភេទប្រុសឋិតក្នុងឋានៈជាបងប្រុសរបស់ភេទស្រីនេះពោលចំពោះភាវរូប តាមច្បាប់ធម្មជាតិ ដែលព្រះ-សម្មាសម្ពុទ្ធទ្រង់ជ្រាប ។

- មិនមែនមានន័យថា បុរសខ្ពង់ខ្ពស់ជាងស្ត្រីក្នុងបុគ្គលបញ្ញត្តិជាទូទៅនោះទេ ព្រោះថា ក្នុងលោកនេះស្ត្រីខ្លះមានការចេះដឹងជាងបុរសខ្លះក៏មាន ទាំងដែលមាន



នូវគុណធម៌ជាងបុរសខ្លះក៏មានដែរ ទាំងដែលជាមាតាជាដើម ។ ដូច្នេះ ត្រូវយល់ដឹងអំពីភាវរូបទាំងពីរ គឺបុរិសភាវរូប និងឥត្ថីភាវរូប ជាបរមត្ថសុទ្ធអាស្រ័យកម្លាំងកម្មជាបច្ច័យដោយឡែក ។

-មិនមែនស្ត្រីត្រូវគោរពបុរស ព្រោះតែរឿងភេទនោះទេ តែត្រូវគោរពដល់គុណធម៌ ។ ព្រះពុទ្ធទ្រង់ត្រាស់ថា «ត្រូវគោរពដល់បុគ្គលដែលគួរគោរព ត្រូវបូជាដល់បុគ្គលដែលគួរបូជា » កូនប្រុសស្រីត្រូវគោរពមាតាបិតា សិស្សត្រូវគោរពគ្រូ ... ដោយមិនប្រកាន់ក្នុងរឿងស្រីប្រុសឡើយ ។

ចប់

## បុណ្យបូជនីយដ្ឋានកម្សាន្តចិត្ត

វក់វីវង្វេងវិលវល់វណ្ឌវាក់ មុនពេលភ្លៀងធ្លាក់ពពកខ្មៅងងឹត
ក្រោយពេលភ្លៀងរួចមេឃប្រែស្រឡះ ចម្បាំងខ្លាំងណាស់ប្រែសុខសាន្តត្រាន ។
រឿងរ៉ាវតូចធំក្នុងក្រុមគ្រួសារ រងទុក្ខខ្លោចផ្សាហួសពីការស្មាន
យសស័ក្តិលាភលុយលួចស្នេហ៍ពីប្រាណ ស្វាមីដូរឡានដូរទាំងភរិយា ។
ទឹកនេត្រាហូររៀងរាល់រាត្រី បាត់បង់ស្វាមីទ្រូងសែនគ្រាំគ្រា
បីបមថ្នមកូនទឹកដល់ប៉ាវ៉ា កូនខ្ញុំកំព្រាវាគេងលក់អស់ ។
ចុះតើមានអ្វីមកទល់ភ្នែកខ្ញុំ នាំឱ្យខ្ញុំយំគេងមិនលក់សោះ
កាលនៅក្រីក្រចិត្តល្អស្មូគ្រស្មោះ លាភយសបុរសក្លាយជាគ្រោះស្រី ។
ទុក្ខធំយ៉ាងហ្នឹងមិនដឹងទៅណា ជិតចេញវស្សាកឋិនឆ្នាំថ្មី
មិត្តភក្តិបបួលស្តាប់ធម៌ទូលត្រៃ សូមជាប់និស្ស័យនឹងព្រះសាសនា ។
ក្រឡេកមើលទង់រហង់ក្បែរពោធិ៍ អណ្តែតលេចធ្លោបក់លើវេហា
នាំពុទ្ធបរិស័ទរីករាយជ្រះថ្លា នឹកឃើញពេលណារសាយកង្វល់ ។
ព្រះធម៌អាចជួយដោះស្រាយទុក្ខបាន ក្មេងចាស់គ្រប់ប្រាណឱ្យតែបានយល់
មិនត្រឹមតែស្រីដែលមានកង្វល់ ទោះប្រុសសំណល់ក៏ធម៌ជួយស្រង់ ។
អស្សុជឆ្នាំកុរថ្ងៃពេញបូណ៌មី បរិស័ទប្រុសស្រីឃ្មាតខ្មីឆ្ពោះត្រង់
ធ្វើបុណ្យរាប់បាត្រប្រគេនព្រះសង្ឃ មួយពាន់ព្រះអង្គពុទ្ធាភិសេក ។



នៅបូជនីយដ្ឋានខេត្តបាត់ដំបង ពេលនោះតែម្តងអស្ចារ្យអនេក
ព្រះពោធិ៍ព្រះពុទ្ធថ្មល្អចម្លែក ពុទ្ធាភិសេកព្រះពុទ្ធរយអង្គ ។
ឆ្លងទាំងអគារពុទ្ធាសនៈ ខឿនពោធិ៍មានថ្នាក់ដាក់មូលដូចកង់
ព្រះនាមព្រះពុទ្ធម្ភៃប្រាំបីអង្គ ឆ្លាក់រៀបផ្ចិតផ្ចង់គ្រប់អង្គឥតទាស់ ។
កន្សែសារពេជ្រដែលជាពិម្ពា ប្រណមវន្ទាសុមេធតាបស
នាងជាភរិយាមានចិត្តសែនស្មោះ គ្រប់ជាតិទាំងអស់ស្មោះនឹងស្វាមី ។
ព្រះបដិមាចារឈ្មោះអ្នកសាង ជាគ្រឿងតំណាងនៃចិត្តភក្តី
បដិមាអង្គធំមានម្ភៃប្រាំបី ព្រះអរិយមេត្តេយ្យជាម្ភៃប្រាំបួន ។
សំណង់អគារពុទ្ធាសនៈ ដំបូលច្រើនថ្នាក់ក្បាច់ឆ្លាក់តាមក្បួន
បុស្បុកទឹកមាសចេញបង្ហាញខ្លួន ឆត្ររួតប្រាំបួនអំពូលពណ៌ថ្មី ។
វាលស្មៅខៀវស្រស់លាស់បង្អួតកាយ បុប្ផាទាំងឡាយលម្អផ្ទៃដី
បង្គោលភ្លើងឈរលម្អរាត្រី ព្រះពោធិ៍ត្រួយខ្ចីខឿនថ្មីភ្លឺថ្លា ។
ស្រះឈូកពោធិ៍ធំកូនភ្នំនិម្មិត ក្រពើស្មៅពិតរូបរាងសង្ហា
ពេលភ្លៀងមានទឹកដូចហែលប្រវា លូនបើកនេត្រាបង្ហាញមហាជន ។
ទន្សាយពោធិសត្វក៏ស្កាត់មកដែរ សម្បុរដូចស្លែរោមស្មៅល្វតល្វន់
ថ្ងៃពេញបូណ៌មីរាត្រីយប់យន់ ទន្សាយគយគន់កណ្តាលដួងខែ ។
ព្រះគន្ធកុដិខ្ពស់ផុតព្រឹក្សា លើស្រះទឹកថ្លាហាក់មានមន្តស្នេហ៍
មានពុទ្ធបរិស័ទចេញចូលហូរហែ គ្រប់គ្នាតែងតែគោរពជ្រះថ្លា ។

ព្រះធម្មចេតិយដូចស្រីគ្រប់លក្ខណ៍ ពេញក្រមុំជាក់តែលាក់ភក្ត្រា
តម្កល់ក្បួនច្បាប់សម្រាប់សិក្សា តែគ្មាននរណាចាប់អារម្មណ៍សោះ ។
រោងម៉ាស៊ីនចាស់ផ្លាស់ទាន់សម័យ រៀបសំពត់ស្បៃតុបតែងឥតទាស់
ក្នុងបូជនីយដ្ឋានអ្វីៗទាំងអស់ សុទ្ធតែល្អស្រស់ហួសពីពណ៌នា ។
រាត្រីថ្ងៃបុណ្យភ្លើងភ្លឺដូចថ្ងៃ ហាក់ដូចបុរីនៃស្ថានសួគ៌ា
អ្នកបានឃើញហើយស្ញើយទុក្ខមួយគ្រា អស្សុជបូជាថ្ងៃចេញវស្សា ។
ម្ភៃប្រាំបីគ្រែសម្លេងផ្សេងផ្ទាត់ តាមពុទ្ធប្រវត្តិកំណត់វាចា
គងលាន់សូរសព្ទប្រាប់ជាសញ្ញា ចប់ធម៌ទេសនាមួយគ្រែវាយម្តង ។
យប់កាន់តែជ្រៅភ្លឺកាន់តែច្បាស់ អង្គុយសំពះខែរះកន្លង
ធម៌កាន់តែច្បាស់ឥតមានសៅហ្មង បញ្ចប់ធម៌ផងដោយបទសរភញ្ញ ។
សូមឱ្យទុក្ខសោករសាត់ផាត់ឆ្ងាយ អ្នកស្អប់ទាំងឡាយក្លាយជាស្រឡាញ់
ចេះធ្វើបុណ្យទានលែងមានកំណាញ់ សុខចិត្តចុះចាញ់បំពេញបារមី ។
សូមគូពីក្មេងលែងបែកបាក់គ្នា ទល់ចាស់ជរានៅតែភក្តី
សូមឱ្យលាភយសរបស់ស្វាមី ចូលដល់ស្ត្រីដែលជាភរិយា ។
សូមមេឃស្រទំកុំដូរអត្ថន័យ ដែលធ្លាប់ស្រដីពេលទើបជួបគ្នា
ស្រទំព្រោះចាញ់សម្រស់ពុំងា កុំឱ្យប្រែជាស្រទំចង់ភ្លៀង ។
សូមឱ្យសព្វសត្វបានសុខសប្បាយ ចាកចេញជិតឆ្ងាយកុំឱ្យដាច់ស្បៀង
ទោះបីជីវិតពិតជាមិនទៀង សូមកុំឱ្យល្មៀងពីសុគតិឡើយ ។

ដោយឧបាសក **គុយ សុធន**



## នាមពុទ្ធបរិស័ទអ្នកមានឧបការៈ
## ក្នុងការងារធម្មទាន

| | |
|---|---|
| ១. ឧបាសក សំរ៉ង វណ្ណ | ២. ឧបាសក យន្ត សួន |
| ៣. ឧបាសក គួង លាងផេង | ៤. ឧបាសក មួង យេន |
| ៥. លោកគ្រូ រស់ សូផាត | ៦. ឧបាសក អ៊ិត ប្រាំង |
| ៧. នាង ជា សុណារី | ៨. ឧបាសិកា ប៊ុត ម៉ាលី |
| ៩. ឧបាសក គុយ សុធន | ១០. ឧបាសក វ៉ាន់ ខុនណា |
| ១១. ឧបាសក សោម រតនៈ | ១២. ឧបាសក ជឹង វ៉េងអ៊ាវ |
| ១៣. ឧបាសក ជឹម ជំនិត | ១៤. ឧបាសក ហាយ ចំរើន |
| ១៥. ឧបាសិកា ហាយ ច័ន្ទធវី | ១៦. លោកគ្រូ ជូ ប៊ុនយូ |
| ១៧. ឧបាសក ង៉ូវ គា | ១៨. ឧបាសក ម៉ៅ ផុន |
| ១៩. ឧបាសិកា ហួនចាន់បូជា | ២០.ឧបាសិកា ស្រី បូរ៉ាន់ |

**សព្វទានំ ធម្មទានំ ជិនាតិ**

ធម្មទានឈ្នះអស់ទានទាំងពួង ។



# I

## ស្ថានីយវិទ្យុ ផ្សព្វផ្សាយព្រះធម៌ព្រះពុទ្ធសាសនា ដោយសហគមន៍ធម្មទាន នៃពុទ្ធបរិស័ទ

| ខេត្ត-ក្រុង | វេលាផ្សាយ | ស្ថានីយវិទ្យុ |
|---|---|---|
| **រាជធានីភ្នំពេញ** | -04h50 mn<br>-05h00 mn<br>-05h30 mn<br>-12h10 mn<br>-18h00 mn<br>-19h00 mn<br>-20h00 mn<br>-20h30 mn | -FM 98 MHz<br>-FM 99 MHz<br>-FM 96 MHz<br>-FM 96 MHz<br>-FM 95 MHz<br>-AM 918 KHz<br>-FM 98 MHz<br>-FM 96 MHz |
| ក្រុងព្រះសីហនុ | -06h00 mn<br>-13h00 mn<br>-17h30 mn | -FM 92 MHz<br>-FM 92 MHz<br>-FM100.5MHz |
| ខេត្តបាត់ដំបង | -05h30 mn<br>-06h00 mn<br>-18h00 mn<br>-18h30 mn<br>-19h30 mn | -FM103.2MHz<br>-FM 92.7MHz<br>-FM 91 MHz<br>-FM 92.7MHz<br>-FM103.2MHz |
| **ក្រុងប៉ៃលិន** | -18h00 mn | -FM 90.5MHz |

**សុខា សទ្ធម្មទេសនា**

ការសម្តែងនូវព្រះសទ្ធម្ម នាំមកនូវសេចក្តីសុខ។

## II

## ស្ថានីយវិទ្យុ ផ្សព្វផ្សាយព្រះធម៌ព្រះពុទ្ធសាសនា ដោយសមាគមន៍ធម្មទាន នៃពុទ្ធបរិស័ទ

| ខេត្ត-ក្រុង | ពេលាផ្សាយ | ស្ថានីយវិទ្យុ |
|---|---|---|
| ខេត្តពោធិ៍សាត់ | -06h00 mn | -FM 98.5 MHz |
| ខេត្តសៀមរាប | -05h00 mn<br>-05h30 mn<br>-18h30 mn | -FM 98 MHz<br>-FM 105.5 MHz<br>-FM 100.5 MHz |
| ខេត្តបន្ទាយមានជ័យ | -05h20 mn<br>-17h00 mn | -FM 96.5 MHz |
| ខេត្តកំពត | -05h00 mn<br>-18h30 mn | -FM 93.25 MHz<br>-FM 103.5 MHz |
| ខេត្តព្រះវិហារ | -18h30 mn | -FM 99 MHz |
| ខេត្តឧត្តរមានជ័យ | -05h00 mn<br>-19h00 mn | -FM 90.25MHz |
| ខេត្តស្ទឹងត្រែង | -18h30 mn | -FM100.5 MHz |
| ខេត្តស្វាយរៀង | -05h30 mn | -FM103.75MHz |

**សុខោ បុញ្ញស្ស ឧច្ចយោ**

ការសន្សំបុណ្យ នាំមកនូវសេចក្តីសុខ ។



## សៀវភៅដែលរៀបរៀងដោយ ខ្ញុំព្រះករុណា ខ្ញុំបាទ

## ✍ ប៊ុត-សាវង្ស ✍


១. ស្ត្រីក្នុងព្រះពុទ្ធសាសនា
២. ជំនួយសតិភាគទី ១ ដល់ភាគទី ១២
៣. មនុស្សជាមួយនឹងការងារ
៤. សិក្ខាបទមនុស្សល្អ
៥. ពរ ៤ ប្រការ
៦. ព្រះពុទ្ធភាសិត ៤៣ គាថា
៧. ខ្លឹមសារគួរយល់ដឹង
៨. ព្រះពុទ្ធសាសនា
៩. កូនមាសឪពុក
១០. ម៉ែ !!!
១១. វិធីរម្ងាប់សេចក្តីក្រោធ
១២. សុខចិត្ត និងគុណភាពនៃជីវិត
១៣. មេរៀនជីវិត
១៤. ពាក្យពេចន៍ម៉ែឪ

១៥. បទពិចារណា

១៦. ពន្លឺធម៌ព្រះពុទ្ធ

១៧. បារមីភាគទី ១ និងខ្លឹមសារខ្លីៗ

១៨. បារមីភាគទី ២ និងខ្លឹមសារខ្លីៗ

១៩. ៤៨ ធម្មទស្សន៍

**សូមអនុមោទនាធម្មទាន !**

**បោះពុម្ពជាធម្មទាន ៩០.០០០ ក្បាល**

**ក្នុងតម្លៃ ១៣.៨០០ ដុល្លារ**

**រោងពុម្ព អ៊ឹម សាវ័ន្ត**

✍📖✍

# មាតិកា


| ឈ្មោះអត្ថបទ | ទំព័រ |
|---|---|
| ១-សិទ្ធិស្ត្រីក្នុងព្រះពុទ្ធសាសនា...................... | ១ |
| ២-បែបបទនិងតួនាទី................................ | ១១ |
| ៣-បញ្ហាបែកបាក់គ្នា................................ | ១៩ |
| ៤-ជីវភាពស្ត្រីជាមួយនឹងព្រះពុទ្ធសាសនា.......... | ៣២ |
| ១-ស្ត្រីធ្វើការក្រៅផ្ទះ......................... | ៣៣ |
| ២-ស្ត្រីមិនមានស្វាមី.......................... | ៣៨ |
| ៣-ស្ត្រីពេស្យាចារ............................ | ៤៥ |
| ៥-សោតិនី.......................................... | ៤៧ |
| ៦-ប្រយោជន៍នៃការសិក្សាព្រះពុទ្ធសាសនាសម្រាប់ស្ត្រី. | ៥៦ |
| ៧-បញ្ហាផ្សេងៗ........................................ | ៧២ |




## ព្រះពុទ្ធដីកា

**ឥត្ថីបិ ហិ ឯកច្ចិយា សេយ្យា បោស ជនាធិប**

**មេធាវិនី សីលវតី សស្សុទេវា បតិព្វតា ฯ**

បពិត្រព្រះអង្គជាធំជាងពពួកជន ដោយពិត ស្ត្រីពួកខ្លះក៏មានកិរិយាមារយាទល្អត្រឹមត្រូវ ជាអ្នកមានសីល មានបញ្ញាឆ្លាតវៃ ប្រណិប័តន៍ឪពុកម្តាយក្មេកដូចទេវតា ព្រមទាំងប្រណិប័តន៍ស្វាមីដោយក្តីស្មោះ សូមព្រះអង្គទ្រង់ចិញ្ចឹមនូវធីតានោះចុះ ព្រោះនាងជាស្ត្រីដ៏ប្រសើរ ។

**តស្សា យោ ជាយតី បោសោ សូរោ ហោតិ ទិសម្បតិ**

**តាទិសា សុភរិយា បុត្តោ រជ្ជម្បិ អនុសាសតីតិ ฯ**

បុរសដែលកើតអំពីស្ត្រីនោះ រមែងជាមនុស្សក្លៀវក្លាជាធំគ្រប់ទិសទី គឺបុត្ររបស់ភរិយាល្អប្រាកដដូច្នោះ តែងប្រៀនប្រដៅពពួកជនដែលនៅក្នុងដែនបាន ។

**ដោយបំណាងល្អដ៏ក្រៃលែង**

**ថ្ងៃ ១៥ កើត ខែកត្តិក ព.ស.២៥៥១**